Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ មគ្គុទេសក៍

## សម្រាប់ការអភិវឌ្ឍប្រព័ន្ធ ទីផ្សារកសិកម្ម



### វិធីសាស្ត្រភ្ជាប់គំនិតអាជីវកម្មកសិករគំរូ

ការណែនាំជាក់ស្តែងសម្រាប់ការជ្រើសរើស កសិករគំរូ ការបណ្តុះបណ្តាល និងការចាប់ផ្តើម អាជីវកម្ម

CHAIN

SNV

swisscontact

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ
# មគ្គុទេសក៍

## សម្រាប់ការអភិវឌ្ឍប្រព័ន្ធ
## ទីផ្សារកសិកម្ម

SNV

swisscontact

## គម្រោងឈេន

### សៀវភៅមគ្គុទេសក៍ សម្រាប់ការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្ម

# វិធីសាស្រ្តភ្ជាស់គំនិតអាជីវកម្មកសិករតូច


**ចងក្រងដោយ៖**
លោកស្រីបណ្ឌិត ឃឹម គឹមបួយ
លោក រិគ អូរើម៉ាស៍
លោក លឹម សុគន្ធដារុណ



**រចនា និងរៀបចំបោះពុម្ពផ្សាយ៖** ក្រុមហ៊ុន អឹម អ  អេ ឌីហ្សាញ
**រៀបចំរូបភាព៖** គម្រោងឈេន
**អ្នកពិនិត្យផ្ទៀងផ្ទាត់៖** លោក រ៉ូណាល់ដូ ម៉ុងតេកាល់វ៉ូ
**បកប្រែជាភាសាខ្មែរ៖** លោក ង៉ែត សុភា

---

**សូមថ្លែងអំណរគុណចំពោះអ្នកពិនិត្យ និងកែសម្រួល៖**
លោកជំទាវបណ្ឌិត យ៉ើ អាស៊ីគិន  អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លោកស្រី ម៉ារិគិ វ៉ាន់ស្ស៊ី ប្រធានគម្រោង អេសអិនវី យូហ្គាន់ដា
លោក រិគ វ៉ាន់ គូលេន ទីប្រឹក្សាបច្ចេកទេស អេសអិនវីសាកល
លោក ហែម សុវណ្ណារិទ្ធ ប្រធានកម្មវិធី ទីភ្នាក់ងារស្វីសសម្រាប់អភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ
បណ្ឌិត សុខ គឹមឈិន ព្រឹទ្ធបុរសនៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
លោក ឱ ធី ប្រធានប្រចាំប្រទេស នៃវិទ្យាស្ថានអន្តរជាតិស្តារជនបទឡើងវិញ
លោក អ៊ុក វណ្ណារ៉ា នាយកប្រតិបត្តិរងនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

**និងសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមចំណែក៖**
លោកស្រី យស មន្នីរ័ត្ន, លោក អ៊ុន រើន, លោក ស្រី សុខជា, លោក សោម សាល
មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

---

**គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ (ឈេន) អេសអិនវី កម្ពុជា និងអគ្គនាយកដ្ឋានកសិកម្ម**

**ខែ ធ្នូ ឆ្នាំ២០២២**

អ៊ីមែល៖ horticulturecambodia@gmail.com
វិបសាយ៖ https://web.maff.gov.kh
ហ្វេសប៊ុក៖ @សាកវប្បកម្មកម្ពុជា Horticulture in Cambodia

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

# បុព្វបទ

វិស័យកសិកម្មនៅប្រទេសកម្ពុជាបានបង្ហាញការបន្តរីកលូតលាស់ទាំងផលិតកម្ម និងការនាំចេញ ទោះបីជាមានការរីករាលដាលនៃជំងឺកូវីត១៩។ ទោះបីយ៉ាងណាក៏ដោយ ភាពក្រីក្រនៅតែជាកត្តាចំបងកើតមានឡើងនៅតំបន់ជនបទ ដែលប្រហែលជា៨០% នៃប្រជាជនក្រីក្រ ២,៥លាននាក់ កំពុងរស់នៅក្នុងតំបន់ជនបទ។ ផលិតភាពទាបនៃកសិករខ្នាតតូចកម្ពុជា ជាលទ្ធផលនៃការប្រើប្រាស់នៅមានកម្រិត នូវធាតុចូលកសិកម្មដែលមានគុណភាព ការអនុវត្តតាមស្តង់ដាបច្ចេកទេស និងនវានុវត្តន៍ ព្រមទាំងឱកាស និងព័ត៌មានទីផ្សារ។ សម្ពាធនៃធនធានធម្មជាតិ និងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមបន្ថែមទៀត។ ចំណែកការចូលរួមក៏នៅមានកម្រិតពីសំណាក់វិស័យឯកជន លើសេវាផ្សព្វផ្សាយកសិកម្ម និងកិច្ចសហការខ្សោយជាមួយតួអង្គមកពីវិស័យសាធារណៈ បានរារាំងការអភិវឌ្ឍភាពរីកចម្រើនរបស់កសិករខ្នាតតូច។ កម្ពុជាពុំទាន់បានផ្គត់ផ្គង់បន្លែក្នុងស្រុកគ្រប់គ្រាន់នៅឡើយម៉្យាងវិញទៀតកំណើនសេដ្ឋកិច្ចរហ័សបានបង្ហាញនូវតម្រូវការកាន់តែខ្ពស់សម្រាប់ការបរិភោគបន្លែនិងផ្លែឈើដែលសុវត្ថិភាព និងគុណភាពល្អ។ កត្តានេះជាឱកាសដ៏មានតម្លៃរបស់កសិករខ្នាតតូច និងអ្នកកែច្នៃ ជាពិសេសស្ត្រី ក្នុងការបង្កើនប្រាក់ចំណូល និងសន្តិសុខស្បៀង។ ជាងនេះទៅទៀត ភាពប្រសើរឡើងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ បានជំរុញការបំលាស់ទីរបស់ប្រជាជនក្រីក្រជនបទ ដោយផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានទីផ្សារចម្រុះ និងឱកាសការងារជាច្រើន។

ឆ្លើយតបទៅនឹងបញ្ហា និងឱកាសទាំងនេះ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) បានអភិវឌ្ឍគម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភដែលហៅកាត់ថា ( គម្រោងឈេន ) ជាកម្មវិធីអភិវឌ្ឍន៍សម្រាប់រយៈពេលប្រាំបីឆ្នាំ ( ២០១៤ - ២០២២ ) ដោយសហការជិតស្និទជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈអគ្គនាយកដ្ឋានកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងបណ្តាខេត្តគោលដៅ។ គម្រោងឈេនបានប្រើប្រាស់វិធីសាស្ត្រអភិវឌ្ឍន៍ទីផ្សារមួយដែលមានគោលបំណងពង្រឹងការចូលរួមរបស់កសិករក្រីក្រ (ផ្តោតសំខាន់លើស្ត្រី) នៅក្នុងទីផ្សារដើម្បីធានានូវលទ្ធភាពប្រើប្រាស់ធាតុចូលកសិកម្ម និងសេវាកម្មបានប្រសើរ និងទទួលបានចំណូលខ្ពស់។ កត្តាគន្លឹះនៃវិធិសាស្ត្រនេះគឺជាដំណើរការសម្របសម្រួលមួយ សម្រាប់ទាក់ទាញការចូលរួមពីបណ្តាដៃគូឯកជន និងសាធារណៈ ព្រមទាំងអង្គការសង្គមស៊ីវិលក្នុងការផ្តល់ជូននូវទំនិញ និងសេវាកម្មនានា ទាំងធាតុចូល និងផលិតផលកសិកម្មនៃច្រវាក់តម្លៃសាកវប្បកម្ម ( ឧទាហរណ៍៖ ការផ្សព្វផ្សាយ ធាតុចូលកសិកម្ម ការរៀបចំទីផ្សារ និងព័ត៌មានទីផ្សារ ) ដែលសាកសម និងបំពេញចំតម្រូវការកសិករក្រីក្រ និងអ្នកកែច្នៃ។ ឆ្លងកាត់រយៈពេល៨ឆ្នាំ យើងអាចសម្រេចបានលទ្ធផលប្រកបដោយផ្លែផ្កា។ ផលិតកម្មលើដំណាំបន្លែរបស់កម្ពុជាបានកើនឡើងគួរអោយកត់សម្គាល់ក្នុងអំឡុងពេល៣ឆ្នាំចុងក្រោយនេះ និងបច្ចុប្បន្នបានគ្របដណ្តប់ ៦៨% នៃតម្រូវការទីផ្សារក្នុងស្រុក ( ៧០០.០០០តោនក្នុងឆ្នាំ២០២០ ) ប្រៀបធៀបនឹង៤២២.០០០តោន ក្នុងឆ្នាំ២០១៣។ សមិទ្ធិផលដ៏អស្ចារ្យ!

សៀវភៅមគ្គុទេសក៍សម្រាប់ការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្មនេះ គឺជាកាប្រមូលផ្តុំឧបករណ៍ គោលការណ៍ ការប្រតិបត្តិ និងវិធីសាស្ត្រនានា ដែលបានអភិវឌ្ឍក្នុងអំឡុងពេលអនុវត្តន៍គម្រោងឈេន។ សៀវភៅនេះនឹងផ្តល់ជាឯកសារយោងសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម ដែលមកពីវិស័យឯកជន វិស័យសាធារណៈ និងសង្គមស៊ីវិលជាដើម។ ជាងនេះទៅទៀត វាក៏ជាសៀវភៅណែនាំមួយសម្រាប់ឆ្ពោះទៅរកនិរន្តរភាពដែលជាស្នូលដ៏សំខាន់សម្រាប់គម្រោងឈេនដោយមានគោលបំណងពង្រឹង ប្រព័ន្ធទីផ្សារសាកវប្បកម្ម និងសមត្ថភាពនៃតួអង្គគ្រប់វិស័យដើម្បីផ្តល់សេវាកម្មទៅកសិករគោលដៅ។ បណ្តាញទំនាក់ទំនង គោលនយោបាយ និងប្រព័ន្ធទីផ្សារដែលបានបង្កើតឡើង នឹងបន្តដំណើរជាតួអង្គពាក់ព័ន្ធគ្រប់វិស័យ ចំណែកឯកសិករនឹងអាចឈានដល់កម្រិតអប្បបរមា-សមស្របមួយ ដើម្បីក្លាយជាទីផ្សារដែលទទួលបានប្រាក់ចំណេញ និងអាចទ្រទ្រង់ខ្លួនឯងបាន។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម អាជ្ញាធរដែនដីថ្នាក់ខេត្ត មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការអភិវឌ្ឍន៍ហូឡង់ (SNV) ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់កិច្ចសហប្រតិបត្តិការដ៏ឥតខ្ចោះ និងសម្រាប់ការរួមចំណែកដ៏មមាញឹកដល់ការអនុវត្តនៃគម្រោងឈេន។



**ម៉ាគុស៍ ប៊ែរលី (Markus Buerli)**
នាយក នៃកិច្ចសហប្រតិបត្តិការ

## មគ្គុទេសក៍ដទៃទៀតមានដាលំដាប់លំដោយដូចខាងក្រោម៖

- សេចក្តីណែនាំស្តីអំពីការអភិវឌ្ឍប្រព័ន្ធទីផ្សារ
- ការសម្របសម្រួលការបង្កើតបណ្តុំកសិ-ធុរកិច្ច
- សម្របសម្រួលទំនាក់ទំនងអាជីវកម្មទៅអាជីវកម្ម (B2B)
- កម្មវិធីជំរុញអាជីវកម្មជនបទ
- ការបង្កើតគម្រោងថវិកាសម្រាប់ដំណាំ
- ដំណោះស្រាយ អាកាសធាតុ និងទឹកឆ្លាតវៃ សម្រាប់សាកវប្បកម្ម
- វីដេអូផលិតដោយកសិករសំរាប់ការផ្សព្វផ្សាយឌីជីថល

# តារាងមាតិកា


| | | |
|---|---|---|
| ១. | សេចក្តីផ្តើម | ១ |
| ២. | ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ | ២ |
| ៣. | ជំហាននៃគំនិតភ្ញាស់អាជីវកម្មកសិករគំរូ | ៦ |
| ៤. | សេចក្តីណែនាំជាជំហានៗ | ៧ |
| ៤.១ | ការកំណត់អត្តសញ្ញាណកសិករគំរូសក្តានុពល | ៧ |
| ៤.២ | ការជ្រើសរើសកសិករគំរូ | ១៥ |
| ៤.៣ | កម្មវិធីបណ្តុះបណ្តាលភ្ញាស់គំនិតអាជីវកម្ម និងការបង្ហាត់បង្ហាញ | ១៦ |
| ៤.៤ | ការវាយតម្លៃលើការរៀនសូត្រ និងអភិវឌ្ឍន៍ផែនការអាជីវកម្ម | ២០ |
| ៤.៥ | ការផ្គូផ្គង និងការគាំទ្រការចាប់ផ្តើមអាជីវកម្ម (ការបង្ហាត់បង្ហាញ និងការផ្តល់ដើមទុនចាប់ផ្តើមអាជីវកម្ម) | ២២ |
| ៥. | សន្និដ្ឋាន | ២៤ |
| ៦. | ឧបសម្ព័ន្ធ | ២៥ |

# ១. សេចក្តីផ្តើម

គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ ហៅកាត់ថា (គម្រោងឈេន) បានផលិតចេញនូវសៀវភៅមគ្គុទេសក៍ (How-to Guides) ជាភាគៗបន្តបន្ទាប់ មានចំណងជើងខុសៗគ្នា ដែលមានខ្លឹមសារជាឯកសារណែនាំព័ត៌មានអំពីការអនុវត្តជាក់ស្តែង សម្រាប់ភាគីពាក់ព័ន្ធដែលមានបំណងចង់ចម្លងតាម និងក៏ចង់ធ្វើការកែលម្អបន្ថែមដើម្បីអោយកាន់តែមានភាពប្រសើរឡើងទៅលើវិធីសាស្ត្រទាំងឡាយដែលគម្រោងឈេនបានប្រើប្រាស់ក្នុងអំឡុងពេលបីវគ្គនៃគម្រោង។ សៀវភៅមគ្គុទេសក៍នីមួយៗផ្តល់នូវទិដ្ឋភាពនៃវិធីសាស្ត្រ ការណែនាំជាជំហានៗ ព័ត៌មានជំនួយ និងអនុសាសន៍ ព្រមទាំងមេរៀនជោគជ័យជាច្រើន។

យើងសង្ឃឹមថាសៀវភៅមគ្គុទេសក៍គ្រប់ភាគទាំងអស់នេះនឹងមានសារៈប្រយោជន៍ទៅដល់ស្ថាប័នផ្សេងៗទូទាំងពិភពលោកដូចជាវិស័យឯកជន សាធារណៈ និងសង្គមស៊ីវិល ជាពិសេសអ្នកដែលធ្វើការងារពាក់ព័ន្ធលើគម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម ព្រមទាំងអនុវត្តន៍វិធីសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ (មើលប្រអប់០១)។ ចំពោះសៀវភៅមគ្គុទេសក៍ទាំងនេះ គម្រោងឈេនបានសហការចងក្រង ជាមួយភាគីពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត។

### ប្រអប់០១៖
### ការអភិវឌ្ឍប្រព័ន្ធទីផ្សារ (MSD)

វិធីសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារគឺគ្របដណ្តប់ប្រព័ន្ធទាំងមូលជុំវិញទីផ្សារ។ ក្នុងករណីសាកវប្បកម្មនេះ ទិដ្ឋភាពរួមនៃទីផ្សារគឺរួមបញ្ចូលអ្នកចូលរួមពាក់ព័ន្ធទាំងអស់ (តួអង្គ ឬអ្នកដើរតួនាទី)៖ កសិករដែលដាំដុះដំណាំ អ្នកផ្គត់ផ្គង់គ្រាប់ពូជ និងអ្នកលក់ធាតុចូលកសិកម្មផ្សេងៗទៅអោយកសិករ អាជីវករដែលទិញផលដំណាំនៅពេលប្រមូលផល និងអ្នកលក់នៅផ្សារនានាទៅអោយអ្នកប្រើប្រាស់ចុងក្រោយ។ សេវាកម្មនានាដែលគាំទ្រជាស្នូលដល់ការងារទីផ្សារ ក៏រួមបញ្ចូលផងដែរ ក្នុងនោះមានដូចជា៖ ភ្នាក់ងារផ្សព្វផ្សាយរដ្ឋាភិបាលដែលផ្តល់ដំបូន្មានទៅកសិករ និងរចនាសម្ព័ន្ធទីផ្សារក្នុងតំបន់ ដែលរៀបចំទីធ្លាសមរម្យល្អសម្រាប់អ្នកលក់ និងអ្នកទិញជួបគ្នា។ ការអភិវឌ្ឍប្រព័ន្ធទីផ្សារមានគោលបំណងដោះស្រាយបញ្ហាភាពក្រីក្រ តាមរយៈការធ្វើអោយប្រសើរឡើងនូវការអនុវត្តទីផ្សារនៅក្នុងបែបផែនបរិយាបន្ន ជាពិសេសការសម្របសម្រួលលើកទឹកចិត្តផ្លាស់ប្តូរឥរិយាបទអាជីវកម្ម និងតួអង្គទីផ្សារដទៃទៀត ដើម្បីធានានូវការផ្លាស់ប្តូរទ្រង់ទ្រាយធំដែលទទួលបានអត្ថប្រយោជន៍យូរអង្វែង។

សៀវភៅមគ្គុទេសក៍មួយនេះផ្តោតលើវិធីសាស្ត្រភ្ជាស់គំនិតអាជីវកម្មកសិករគំរូ។ កសិករគំរូ គឺជាកសិករដែលដើរតួជាជនបង្គោលទំនាក់ទំនងនៅក្នុងសហគមន៍ជាគំរូក្នុងការអនុវត្តកសិកម្មរបស់ពួកគេ ព្រមទាំងជាអ្នករៀបចំចាត់ចែង និងទំនាក់ទំនងល្អ។ ជាធម្មតាពួកគេជាអ្នកដឹកនាំមិនផ្លូវការទៅកាន់ក្រុមកសិករ និងត្រូវបានទទួលស្គាល់ដោយកសិករ និងសមាជិកសហគមន៍ដទៃទៀត។ កសិករគំរូបំពេញកិច្ចការនិងទំនួលខុសត្រូវនានាជាក់លាក់នៅក្នុងគម្រោង ឬសម្របសម្រួលសកម្មភាពផ្សេងៗសម្រាប់ក្រុមហ៊ុន។ ពួកគេអាចបង្កើតទំនាក់ទំនងបានរឹងមាំជាមួយក្រុមកសិករនៅក្នុងភូមិ និងដើរតួជាអ្នកទំនាក់ទំនងចម្បងសម្រាប់គម្រោង ក្រុមហ៊ុន ឬអង្គការដៃគូនានា។

ក្នុងអំឡុងពេលអនុវត្តន៍នៃគម្រោងឈេន យើងបានសហការជាមួយដៃគូជាច្រើនរួមមាន៖ អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនវិស័យឯកជន។ យើងបានជួយតួអង្គទីផ្សារទាំងនេះក្នុងការផ្តល់ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់ក្រុមកសិករ សម្របសម្រួលការផ្សារភ្ជាប់ទីផ្សារ គាំទ្រលទ្ធភាពទទួលបានព័ត៌មានទីផ្សារ និងធាតុចូលកសិកម្ម សម្របសម្រួលរៀបចំផែនការផលិតកម្ម និងទំនាក់ទំនងជាមួយរដ្ឋាភិបាល។ ប៉ុន្តែយើងមិនអាចរំពឹងថាដៃគូទាំងនេះនឹងបន្តការតាមដានយ៉ាងមុតមាំទៅលើសកម្មភាពកសិករដោយគ្មានការគាំទ្រពីគម្រោងនោះទេ។ កសិករគំរូអាចបន្តសកម្មភាពទាំងអស់នេះ (ពួកគេប្រហែលអាចទទួលបានប្រាក់ឧបត្ថម្ភតិចតួច ឬការលើកទឹកចិត្តដទៃទៀតពីគម្រោង) ប៉ុន្តែជាធម្មតាពួកគេបញ្ចប់កិច្ចការទាំងនោះនៅពេលគម្រោងត្រូវបានបញ្ចប់ដែរ។ ហេតុដូច្នេះហើយ យើងបានចងក្រងគំរូអាជីវកម្មខ្នាតតូចមួយដែលកសិករគំរូអាចធ្វើការងារដើម្បីបន្តផ្តល់សេវាកម្មបាន។ យើងបានចាប់ផ្តើមដោយជ្រើសរើសកសិករគំរូដែលអាចផ្តួចផ្តើមអាជីវកម្មខ្នាតតូចជាមួយនឹងគំរូសេវាកម្មផ្សព្វផ្សាយមួយ។ កសិករគំរូថ្មីម្នាក់គឺជាកសិករដាំបន្លែម្នាក់ដែលមានបទពិសោធន៍បច្ចេកទេសល្អ និងមានសក្តានុពលក្នុងការគ្រប់គ្រងអាជីវកម្ម ព្រមទាំងមានឆន្ទៈដើម្បីក្លាយជាសហគ្រិនខ្នាតតូច។ កសិករគំរូចាំបាច់ត្រូវចូលរួមកម្មវិធីកសាងសមត្ថភាពមុនពេលពួកគេអាចដើរតួនាទីជាអ្នកគាំទ្រផ្នែកបច្ចេកទេស ទីផ្សារ និងចែកចាយធាតុចូលកសិកម្ម ព្រមទាំងជាភ្នាក់ងារផ្សព្វផ្សាយសម្រាប់កសិករដទៃទៀតនៅក្នុងសហគមន៍។

គម្រោងឈេនបានចាប់ផ្តើមធ្វើការជាមួយកសិករគំរូនៅក្នុងឆ្នាំ២០១៨។ កសិករគំរូចំនួន៦០នាក់ត្រូវបានជ្រើសរើសក្នុងឆ្នាំដំបូងហើយទទួលបានការគាំទ្រអំពីគំនិតភ្ញាស់អាជីវកម្ម។ ត្រឹមឆ្នាំ២០២០កសិករចំនួន៤០នាក់បានចាប់ផ្តើមអាជីវកម្មរបស់ខ្លួនក្រៅពីការងារដាំដំណាំ។ នៅក្នុងឆ្នាំ២០២១ កសិករគំរូចំនួន៥០នាក់បន្ថែមទៀតត្រូវបានជ្រើសរើស។

# ២. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ

## អ្វីទៅជាបញ្ហា?

នៅពេលគម្រោងឈេនបានចាប់ផ្តើម កសិករដាំបន្លែទទួលបានការគាំទ្រចំណេះដឹង និងសម្ភារៈមិនគ្រប់គ្រាន់ ឬតិចតួច មិនមានលទ្ធភាពទទួលបានព័ត៌មានទីផ្សារទាន់ពេល និងមានការលំបាកក្នុងការទទួលបានធាតុចូលកសិកម្មដែលមានគុណភាព។ គម្រោងឈេនបានរកឃើញថា ខណៈពេលកសិករមួយចំនួនសម្រេចបានលទ្ធផលល្អនៅក្នុងការដាំដុះបន្លែ និងប្រើប្រាស់បច្ចេកវិទ្យាសាកវប្បកម្មទំនើបៗដូចជា៖ ប្រព័ន្ធដំណក់ទឹក និងកៅស៊ូគ្របរងជាដើម មានអ្នកជិតខាងរបស់ពួកគេជាច្រើននៅក្នុងភូមិតែមួយ មិនបានអនុវត្តតាមការដាំដុះដោយប្រើបច្ចេកវិទ្យាឆ្លាតវៃដូចពួកគេឡើយ។ ដោយយល់ឃើញថា ការផ្ទេរចំណេះដឹងនៅមិនទាន់បានពេញលេញរវាងកសិករ និងដៃគូរបស់ពួកគេ ក្រុមការងារគម្រោងឈេន បានចាប់ផ្តើមគិតអំពីវិធីសាស្ត្រជ្រើសរើសកសិករដែលជោគជ័យបំផុត និងបណ្តុះបណ្តាលពួកគេ ដើម្បីឱ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាព និងដើរតួនាទីនៅក្នុងការសម្របសម្រួលសកម្មភាពទីផ្សារ ទំនាក់ទំនងព័ត៌មាន លើកទឹកចិត្តសមាជិកក្រុម និងសកម្មក្នុងការសម្របសម្រួលទំនាក់ទំនងអាជីវកម្មនានា។ គម្រោងឈេនមានក្តីបារម្ភអំពីនិរន្តរភាពនៃអន្តរាគមន៍ខ្លួនបន្ទាប់ពីការអនុវត្តគម្រោងត្រូវបានបញ្ចប់ ក្នុងន័យនេះផងដែរ យើងយល់ឃើញថាកសិករគំរូគឺជាតួអង្គដើរតួនាទីដ៏សំខាន់។ កសិករគំរូចាំបាច់ត្រូវការ-ការលើកទឹកចិត្តផ្នែកអាជីវកម្មដើម្បីបំពេញលើតួនាទីនេះ ហើយពួកគេទំនងជាអាចបន្តដើរតួជាកសិករគំរូដ៏ក្លៀវក្លា ប្រសិនបើការបន្តនេះនៅតែអាចផ្តល់ឱកាសអាជីវកម្មដល់ពួកគេ។

## អ្វីទៅដែលរំពឹងថានឹងសម្រេចបាន?

គម្រោងឈេនបានរៀបចំដំណោះស្រាយដែលយើងជឿជាក់គឺ៖ (១) កាត់បន្ថយបន្ទុកការងារសម្រាប់ទាំងបុគ្គលិកគម្រោង និងបុគ្គលិកដៃគូរបស់គម្រោង (២) ផ្តល់ចំណេះដឹងបច្ចេកទេស ព្រមទាំងជំនាញអាជីវកម្ម និងភាពជាអ្នកដឹកនាំ ទៅដល់កសិករគំរូ (៣) បង្កើនទំនុកចិត្តដល់កសិករគំរូក្នុងការផ្ទេរចំណេះដឹងទៅកាន់កសិករផ្សេងទៀត និង (៤) ពង្រឹងបុគ្គលិកគម្រោង សមត្ថភាពដៃគូ ដើម្បីពួកគេអាចផ្តល់សេវាកម្មរួមគ្នាទៅក្រុមកសិករ អភិវឌ្ឍសហគ្រាសខ្នាតតូចបន្ថែមទៀត និងគាំទ្រដល់វិស័យឯកជនក្នុងការពង្រីកទីផ្សារ និងណែនាំគំនិតថ្មីៗនៅក្នុងតំបន់គោលដៅ។ យើងចង់ឃើញកសិករគំរូនៅក្នុងសហគមន៍/ភូមិ ចេះបង្រៀន បង្ហាត់បង្ហាញ និងចែករំលែកចំណេះដឹងជាមួយក្រុមកសិករដើម្បីធ្វើអោយប្រសើរឡើងនូវជំនាញបច្ចេកទេស និងអភិវឌ្ឍផ្នត់គំនិតអាជីវកម្ម។ គម្រោងឈេនបានរៀបចំកម្មវិធីភ្ញាស់គំនិតអាជីវកម្មដើម្បីជួយដល់កសិករដែលមានចំណាប់អារម្មណ៍ ក្នុងការចាប់ផ្តើមអាជីវកម្មខ្នាតតូចនានា ដែលអាចរកចំណូលបានបន្ថែម ព្រមទាំងជួយដោះស្រាយនូវគម្លាតទីផ្សារ ។

## អ្វីទៅជាដំណោះស្រាយ/យុទ្ធសាស្ត្រ?

កម្មវិធីបណ្តុះបណ្តាលដែលបានបង្កើតឡើងសម្រាប់គោលបំណងដូចបញ្ជាក់ខាងលើនេះ ត្រូវបានគេកំណត់ឈ្មោះថា « ការភ្ញាស់គំនិតអាជីវកម្មកសិករគំរូ » ដោយរួមបញ្ចូលទាំងការបណ្តុះបណ្តាលបច្ចេកទេស និងកម្មវិធីសិក្សាអាជីវកម្មដែលមានប្រាំជំហានដូចខាងក្រោម៖



១. ការកំណត់អត្តសញ្ញាណកសិករគំរូដែលមានសក្តានុពល



២. ការជ្រើសរើសកសិករគំរូ



៣. ការបណ្តុះបណ្តាលគំនិតភ្ញាស់អាជីវកម្ម និងកម្មវិធីបង្ហាត់បង្ហាញ



៤. អភិវឌ្ឍន៍ផែនការអាជីវកម្ម



៥. ការផ្គូផ្គង និងការគាំទ្រការចាប់ផ្តើមអាជីវកម្ម

# លទ្ធផល

ការភ្ជាស់គំនិតអាជីវកម្មកសិករគំរូ ត្រូវបានដាក់បញ្ចូលជាមួយអន្តរាគមន៍ផ្សេងៗរបស់គម្រោងឈេន ដែលបានផលិតចេញជាលទ្ធផលដ៏រឹងមាំ នៅក្នុងបណ្តាខេត្តគោលដៅ៖

- កសិករគំរូចំនួន ១០៩ នាក់ ត្រូវបានជ្រើសរើស។
- កសិករគំរូចំនួន៥០នាក់ (៤៧% ជាស្ត្រី) បានចាប់ផ្តើមអាជីវកម្មខ្នាតតូចរបស់ខ្លួន និងបានផ្តល់សេវាកម្មទៅកាន់ដៃគូរបស់ពួកគេ។
- កសិករគំរូភាគច្រើនបានអនុវត្តនូវអ្វីដែលពួកគេបានរៀនពីកម្មវិធីបណ្តុះបណ្តាលទៅក្នុងសកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់ពួកគេ
- ៧៦% នៃចំនួនកសិករគំរូដែលបានបញ្ចប់កម្មវិធីកសាងសមត្ថភាពបានចាប់ផ្តើមអាជីវកម្មផ្សេងៗ ខណៈដែល ២៤% នៃកសិករគំរូដទៃទៀតពុំទាន់បានចាប់ផ្តើមអាជីវកម្មនៅឡើយឬពួកគេបានបោះបង់ការចូលរួមក្នុងកម្មវិធីនេះ។
- ក្នុងចំណោមកសិករគំរូដែលបានបញ្ចប់កម្មវិធីភ្ញាស់គំនិតអាជីវកម្មដោយជោគជ័យ មានកសិករគំរូ ៥៣% ក្លាយជាអ្នកប្រមូលទិញបន្លែ ៣៩% ជាភ្នាក់ងារចែកចាយធាតុចូលកសិកម្ម និង ៨% ជាអ្នកផ្គត់ផ្គង់កូនដំណាំ។
- ជាលទ្ធផលក្រោយពេលទទួលបានការបណ្តុះបណ្តាលបច្ចុប្បន្នកសិករគំរូអាចគ្រប់គ្រងការចំណាយ និងចំណូល ព្រមទាំងអាចកសាងទំនាក់ទំនងអាជីវកម្មជាមួយក្រុមហ៊ុនប្រមូលទិញនិងអតិថិជននានា។
- អាជីវករលក់បន្លែចំនួន ២០នាក់ និងអ្នកលក់ធាតុចូលកសិកម្មចំនួន២៥នាក់ បានសហការ និងធ្វើការតាមរយៈកសិករគំរូដែលគាំទ្រដោយគម្រោងឈេន និងបានពង្រីកទំនាក់ទំនងអាជីវកម្មរបស់ពួកគេ។
- ក្រុមហ៊ុនវិស័យឯកជនថ្នាក់ជាតិចំនួន៦ក្រុមហ៊ុន បានសហការនិងធ្វើការទាំងផ្លូវការនិងមិនផ្លូវការជាមួយកសិករគំរូដែលគាំទ្រដោយគម្រោងឈេន និងបានពង្រីកកិច្ចខំប្រឹងប្រែងអាជីវកម្មរបស់ពួកគេ នៅក្នុងបណ្តាខេត្តគោលដៅ។
- ដៃគូរបស់គម្រោងនៅថ្នាក់ក្រោមជាតិមួយចំនួនបានផ្តល់ព័ត៌មានថាទស្សនៈរបស់ពួកគេបានផ្លាស់ប្តូរតាមរយៈវដ្តជីវិតរបស់គម្រោងឈេន ហើយពួកគេបានយល់ច្បាស់អំពីអត្ថប្រយោជន៍នៃការលើកទឹកចិត្តកសិករឱ្យមានគំនិតដូចអ្នកជំនួញនិងបង្កើនទំនាក់ទំនងទៅគ្រប់តួអង្គពាក់ព័ន្ធនៅក្នុងទីផ្សារ។
- ៩៦% នៃចំនួនកសិករគំរូដែលបានចាប់ផ្តើមអាជីវកម្មខ្នាតតូចបានបង្កើនដើមទុនរបស់ពួកគេ។
- កសិករគំរូភាគច្រើន (៩៥%) បច្ចុប្បន្នមានការយល់ដឹងបានប្រសើរទៅលើបច្ចេកវិទ្យាក្នុងការដាំដុះបន្លែ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងទំនាក់ទំនងបានធំទូលាយជាមួយកសិករនិងអាជីវករដទៃៗទៀត។
- កសិករគំរូភាគច្រើនកាន់តែមានទំនុកចិត្តផ្ទាល់ខ្លួនក្នុងការជួយគាំទ្រកសិករដទៃទៀតដើម្បីដោះស្រាយបញ្ហាលើផលិតកម្មដំណាំដូចជាការគ្រប់គ្រងជំងឺ សត្វល្អិត និងការគ្រប់គ្រងទឹក។



# បទពិសោធន៍របស់គម្រោងឈេន



## កសិករគំរូ ខេត្តឧត្តរមានជ័យ

អ្នកមីង ហ៊ុយ យៀន ជាកសិករដាំបន្លែ អ្នកលក់ដុំ និងលក់រាយ ដែលមានទីលំនៅ នៅស្រុកអន្លង់វែង នៃខេត្តឧត្តរមានជ័យ។ គាត់គឺជាប្រធានក្រុមកសិករផលិតនៅក្នុងភូមិសន្តិភាព។ លោកស្រីបានចូលរួមសកម្មភាពជាមួយគម្រោងឈេនតាំងពីដំណាក់កាលទី១នៃគម្រោង និងបានរៀនសូត្រអំពីរបៀបធ្វើអោយប្រសើរឡើងនូវអាជីវកម្មលក់បន្លែរបស់គាត់ ដោយមានការគាំទ្រពីក្រុមការងារគម្រោង។ គាត់មានប្រសាសន៍ថា « អាយុមិនមែនជាបញ្ហា ហើយក៏មិនបានរារាំងដល់ដំណើរការរៀនសូត្ររបស់ខ្ញុំដែរ »។ ដោយបានចូលរួមកម្មវិធីភ្ញាស់គំនិតអាជីវកម្ម លោកស្រីបានរៀនសូត្រនូវគំនិតគន្លឹះៗពី « គំរូអាជីវកម្មខេនវ៉ាស (Business Model Canvas) គឺការសិក្សាតាមរយៈរូបភាពនៃដុំតដ្ឋប្រាំបួនដុំដែលត្រូវបានដាក់បន្តុបជាមួយគ្នា បានឱិតជាប់ និងជាការចងចាំមិនភ្លេចរបស់គាត់។ ចាប់តាំងពីពេលនោះមកលោកស្រីបានយកមកអនុវត្តជាប្រចាំនូវអ្វីដែលគាត់បានរៀនដូចជារបៀបកត់ត្រាចំណាយ និងការលក់។ អ្វីៗដែលលោកស្រីបានរៀនពីគម្រោងឈេន បានដឹកនាំគាត់ទៅរកភាពជោគជ័យនៃអាជីវកម្ម និងទទួលបានប្រាក់ចំណូលខ្ពស់ ដូច្នេះបច្ចុប្បន្នលោកស្រីអាចផ្គត់ផ្គង់កូនៗ២នាក់របស់គាត់ដែលកំពុងបន្តការសិក្សានៅសាកលវិទ្យាល័យ។



## កសិករគំរូ ខេត្តស្ទឹងត្រែង

លោក កែវ ឧត្តម គឺជាកសិករគំរូម្នាក់ រស់នៅក្នុងភូមិរាជានុកូល នៃខេត្តស្ទឹងត្រែង។ ថ្មីៗនេះគាត់បានចូលរួមក្នុងកម្មវិធីរបស់គម្រោង។ គាត់គឺជាកសិករវ័យក្មេងដែលមានគំនិតច្នៃប្រឌិត ហើយតែងតែស្វែងរកដំណោះស្រាយនៅលើប្រព័ន្ធ YouTube នៅពេលដែលគាត់មានបញ្ហាប្រឈមទៅលើផលិតកម្មបន្លែរបស់គាត់។ គាត់ទទួលស្គាល់ថា កិច្ចខំប្រឹងប្រែងរបស់គាត់ដើម្បីឱ្យបច្ចេកទេសដាំដុះមានភាពប្រសើរឡើង ជួនកាលទទួលបរាជ័យ ប៉ុន្តែអ្វីៗបានប្រសើរឡើងគួរអោយកត់សម្គាល់បន្ទាប់ពីរូបគាត់ទទួលបានការបង្ហាត់បង្ហាញពីកសិករគំរូដទៃទៀត ដែលបានលើកទឹកចិត្តគាត់ឱ្យចូលរួមនៅក្នុងកម្មវិធីភ្ញាស់គំនិតអាជីវកម្មនេះ។ ដោយបានបញ្ចប់នូវវគ្គបណ្តុះបណ្តាលសព្វគ្រប់ បច្ចុប្បន្នគាត់បានយល់ដឹងអំពីផ្នត់គំនិតអាជីវកម្ម រួមមាន សហគ្រិនភាព និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចជាមូលដ្ឋាន។

*« បានរៀនសូត្រច្រើនពីកម្មវិធីភ្ញាស់គំនិតអាជីវកម្ម ដូចជាការរៀបចំផែនការអាជីវកម្ម ការគ្រប់គ្រងអាជីវកម្ម និងទីផ្សារ និងការកត់ត្រាចំណូលចំណាយ។ ពេលនេះ ខ្ញុំមានទំនុកចិត្តច្រើនជាងមុនក្នុងការគ្រប់គ្រងអាជីវកម្មផ្ទាល់ខ្លួនរបស់ខ្ញុំក្នុងនាមជាអ្នកផ្គត់ផ្គង់សេវាតម្លើងប្រព័ន្ធដំណក់ទឹក បន្ថែមពីមុខរបររបស់ខ្ញុំជាអ្នកដាំដុះបន្លែសព្វថ្ងៃ។ »*



## ទីប្រឹក្សាបច្ចេកទេស សាកវប្បកម្ម

លោក សៀង វ៉ាន់ស៊ីថា អាយុ ៣២ឆ្នាំ ជាទីប្រឹក្សាបច្ចេកទេស បាន និងកំពុងចូលរួមក្នុងសកម្មភាពរបស់គម្រោងឈេន វគ្គ៣ ចាប់តាំងពីដើមឆ្នាំ២០២១។ តួនាទីចំបងរបស់គាត់គឺផ្តល់ការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យាសាកវប្បកម្មដល់មន្ត្រីបង្គោលមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងអ្នកសម្របសម្រួលទីផ្សារប្រចាំខេត្ត និងអ្នកបច្ចេកទេសកសិកម្មវ័យក្មេង នៅក្នុងបណ្តាខេត្តគោលដៅរបស់គម្រោង។ គាត់ក៏ធ្លាប់ជាទីប្រឹក្សាបច្ចេកទេសនៃវិស័យឯកជន ដោយបានធ្វើការស្រាវជ្រាវ និងផ្តល់ការបណ្តុះបណ្តាលដល់ក្រុមកសិករជាច្រើន។ ជាមួយគម្រោងឈេន គាត់មានឱកាសក្នុងការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោង។ គាត់យល់ឃើញថា ការភ្ញាស់គំនិតអាជីវកម្មកសិករគំរូ គឺមានសារៈសំខាន់ ពីព្រោះកសិករគំរូអាចទទួលបានដំណោះស្រាយទាន់ពេលវេលាផ្អែកទៅលើបញ្ហារបស់ពួកគេ ពីសំណាក់បុគ្គលិក និងមន្ត្រីថ្នាក់ខេត្ត ហើយអាចចែករំលែកដំណោះស្រាយល្អៗទាំងនោះជាមួយអ្នកដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ។ កម្មវិធីភ្ញាស់គំនិតអាជីវកម្ម ផ្តល់នូវកម្មវិធីសិក្សាផ្នែកបច្ចេកទេសកសិកម្ម ការកំណត់អត្តសញ្ញាណជំងឺ ការពិនិត្យរកមើលសត្វល្អិត ឬជំងឺលើដំណាំ និងការរៀបចំថ្នាលដំណាំទៅដល់បុគ្គលិកដៃគូរបស់គម្រោងនៅថ្នាក់ក្រោមជាតិ ដែលពួកគេនឹងធ្វើការបណ្តុះបណ្តាលបន្តដល់កសិករគំរូ។

*« ខ្ញុំរៀនសូត្របានច្រើនក្នុងអំឡុងពេលចូលរួមសកម្មភាពជាមួយគម្រោងឈេន និងទទួលបានឱកាសបណ្តុះបណ្តាលបុគ្គលិកផ្សព្វផ្សាយនានាអំពីបច្ចេកវិទ្យាមួយចំនួនដែលមានភាពងាយស្រួលក្នុងការអនុវត្ត ខ្ញុំអាចនិយាយបានថាកសិករគំរូបានបង្ហាញការរីកចំរើនយ៉ាងឆាប់រហ័សទាក់ទងនឹងចំណេះដឹងបច្ចេកទេស បន្ទាប់ពីបានចូលរួមក្នុងកម្មវិធីភ្ញាស់គំនិតអាជីវកម្មនេះ និងមានសមត្ថភាពបង្រៀនកសិករដទៃទៀតបាន។ »*



## មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង

កញ្ញា ខៃ ដាលីន ជាមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាំងពីឆ្នាំ២០១៧ ប៉ុន្តែពេលនោះគាត់មិនមានបទពិសោធន៍ច្រើនក្នុងផលិតកម្មដំណាំ ឬការអភិវឌ្ឍអាជីវកម្មបន្លែទេ។ ខណៈពេលកំពុងបំពេញការងារជាមួយគម្រោងឈេន គាត់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលមួយចំនួនរួមមាន បច្ចេកទេសដាំដុះដំណាំ បញ្ហាយេនឌ័រ និងការអភិវឌ្ឍអាជីវកម្ម។ ជាងនេះទៅទៀត កញ្ញាទទួលបានឱកាសចូលរួមទស្សនកិច្ចសិក្សាទៅកាន់បណ្តាខេត្តផ្សេងៗ ដើម្បីស្វែងយល់នូវសកម្មភាពទាក់ទងនឹងកសិកម្មមួយចំនួន។ នៅពេលដាលីនបានចូលរួមកម្មវិធីភ្ញាស់គំនិតអាជីវកម្ម គាត់បានរៀនសូត្រលើជំនាញគ្រប់គ្រងហិរញ្ញវត្ថុ ភាពជាអ្នកដឹកនាំ និងផ្ទត់គំនិតអាជីវកម្ម តាមរយៈអ្នកជំនាញអាជីវកម្មមកពីសហគ្រិន « SHE Investment » ។ កម្មវិធីក៏បានរួមបញ្ចូលផងដែរនូវវគ្គសិក្សាបច្ចេកទេសដំណាំដែលបង្ហាត់បង្ហាញដោយទីប្រឹក្សាបច្ចេកទេសដែលមានបទពិសោធន៍ខ្ពស់។

*« ចំណេះដឹងរបស់ខ្ញុំបានចាប់ផ្តើមពីចំណុចសូន្យ ប៉ុន្តែបច្ចុប្បន្ននាងខ្ញុំយល់ដឹងបានច្រើនដូចជា ចំណេះដឹងសាកវប្បកម្ម និងជំនាញអាជីវកម្មនានា ហើយនាងខ្ញុំទទួលបាននូវអ្វីៗទាំងអស់នេះ គឺតាមរយៈគម្រោងឈេន ព្រោះប្រសិនបើមិនបានចូលរួមក្នុងគម្រោងឈេននោះទេ នាងខ្ញុំគិតថានឹងមិនអាចទទួលបានលទ្ធផលប្រសើរដូចសព្វថ្ងៃនេះទេ។ »*

# ៣. ជំហាននៃគំនិតភ្ញាស់អាជីវកម្មកសិករគំរូ

តារាងខាងក្រោម បង្ហាញជាសង្ខេបនូវវិធីសាស្ត្រភ្ញាស់គំនិតអាជីវកម្មកសិករគំរូទាំង៥ជំហាន៖

| | ជំហានវិធីសាស្ត្រ | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ការកំណត់អត្តសញ្ញាណកសិករគំរូសក្តានុពល | • កំណត់តួនាទី និងទំនួលខុសត្រូវ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសកសិករគំរូ<br>• កំណត់អត្តសញ្ញាណកសិករគំរូដែលមានសក្តានុពលគំរូផែនការផលិតកម្ម<br>• អភិវឌ្ឍផែនការដើម្បីធ្វើឱ្យតួនាទីរបស់កសិករគំរូទាំងនោះមាននិរន្តរភាព | • បញ្ជីពត៌មាននៃតួនាទី និងទំនួលខុសត្រូវ ដែលបានរំពឹងទុកសម្រាប់កសិករគំរូ<br>• លក្ខណៈវិនិច្ឆ័យសំរាប់ការជ្រើសរើស<br>• បញ្ជីឈ្មោះកសិករគំរូដែលមានចំណាប់អារម្មណ៍ |
| ២ | ការជ្រើសរើស និងការចុះបញ្ជីឈ្មោះកសិករគំរូ | • ធានាថាតួនាទី និងទំនួលខុសត្រូវ ព្រមទាំងប្រភេទនៃជម្រើសអាជីវកម្មសម្រាប់កសិករគំរូ មានភាពជាក់លាក់ និងយល់ច្បាស់<br>• ចុះបញ្ជីកសិករគំរូដែលបានកំណត់អត្តសញ្ញាណរួចរាល់ | • បញ្ជីនៃការជ្រើសរើស និងការចុះបញ្ជីកសិករគំរូ |
| ៣ | កម្មវិធីបណ្តុះបណ្តាលភ្ញាស់គំនិតអាជីវកម្ម | • ធានាថាកសិករគំរូមានជំនាញសហគ្រិន ផ្សព្វផ្សាយ និងជំនាញបច្ចេកទេសកសិកម្មបានល្អកំណត់<br>• ធានាថាកសិករគំរូមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអាជីវកម្មថ្មីរបស់ពួកគេដើម្បីទទួលបានប្រាក់ចំណេញ | • ចំណេះដឹង និងជំនាញបច្ចេកទេសកើនឡើងទាក់ទងនឹងសាកវប្បកម្ម និង ក្សេត្រសាស្ត្រ<br>• កសិករគំរូអាចបណ្តុះបណ្តាលបន្តទៅកសិករដទៃទៀត និងចែករំលែកចំណេះដឹងជាមួយពួកគេ<br>• ពង្រឹងជំនាញគ្រប់គ្រងអាជីវកម្ម និងសហគ្រិនភាព |
| ៤ | អភិវឌ្ឍផែនការអាជីវកម្ម | • អភិវឌ្ឍផែនការអាជីវកម្មដើម្បីជួយកសិករគំរូចាប់ផ្តើមអាជីវកម្មខ្នាតតូចរបស់ពួកគេ | • ផែនការចាប់ផ្តើមអាជីវកម្ម |
| ៥ | ផ្គត់ផ្គង់ និងគាំទ្រការចាប់ផ្តើមអាជីវកម្ម | • ធានាបាននូវលទ្ធភាពជោគជ័យនៃអាជីវកម្ម<br>• ចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម | • ចុះកិច្ចសន្យារវាងកសិករគំរូនិងដៃគូអាជីវកម្មនានា<br>• ទំនាក់ទំនងអាជីវកម្មត្រូវបានបង្កើតឡើង |

# ៤. សេចក្តីណែនាំជាជំហាន។

## ៤.១ ការកំណត់អត្តសញ្ញាណកសិករគំរូសក្តានុពល

ជាការពិតគឺមានភាពលំបាកដឹងថានឹងត្រូវទាក់ទងទៅនរណាដើម្បីកំណត់អត្តសញ្ញាណកសិករគំរូដែលមានសក្តានុពល។ ទី១អ្នកអាចប្រមូលព័ត៌មានដ៏ប្រវត្តិពីការទាក់ទងដោយផ្ទាល់ជាមួយដៃគូគម្រោង នាយកដ្ឋានរបស់រដ្ឋាភិបាលនានា និងអង្គការក្រៅរដ្ឋាភិបាលនៅក្នុងតំបន់គោលដៅ។ ទី២ អ្នកអាចកំណត់នូវធាតុសំខាន់ៗដែលកសិករគំរូគួរធ្វើ និងបុគ្គលិកលក្ខណៈបែបណាដែលគាត់គួរមាន។ កត្តានេះគួរត្រូវបានធ្វើឡើងជាវិធីសាស្ត្រដែលមានការចូលរួមជាមួយតួអង្គទីផ្សារ និងកសិករខ្លួនឯង - ពីព្រោះពួកគេផ្ទាល់គឺជាអ្នកដែលនឹងត្រូវធ្វើការជាមួយកសិករគំរូ។ ទី៣ បញ្ជីឈ្មោះកសិករគំរូសក្តានុពលគួរត្រូវបានរៀបចំរួមទាំងផែនការសម្ភាសន៍ ដើម្បីជំរុញទឹកចិត្ត និងជ្រើសរើសពួកគេ។

**កំណត់ចំណាំគន្លឹះ៖**
គម្រោងអភិវឌ្ឍន៍ ជាធម្មតាជ្រើសរើសអ្នកដឹកនាំភូមិ ឬសហគមន៍ជាកសិករគំរូ។ ពួកគេគឺជាអ្នកដែលមានទេពកោសល្យពីធម្មជាតិ និងជារឿយៗដើរតួជាបង្គោលទំនាក់ទំនងសម្រាប់គម្រោងអភិវឌ្ឍន៍នានា។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេប្រហែលជាមិនមែនជាបេក្ខភាពដ៏ល្អបំផុត សម្រាប់ដើរតួជាកសិករគំរូនោះទេ ពីព្រោះពួកគេប្រហែលមិនមែនជាកសិករមានបទពិសោធន៍ល្អលើផលិតកម្មដំណាំ ហើយក៏អាចខ្វះជំនាញបច្ចេកទេស ឬការយល់ដឹងអំពីអាជីវកម្មផងដែរ។ ដូចគ្នានេះដែរ ពួកគេអាចនៅមានលក្ខណៈអភិរក្ស និងប្រពៃណីនិយម នៅពេលនវានុវត្តន៍ និងការលើកកម្ពស់បច្ចេកវិទ្យាត្រូវការចាំបាច់។ ជាងនេះទៅទៀត ភាគច្រើននៃបេក្ខភាពទាំងនោះគឺជាបុរស ទោះបីជាអ្នកដាំបន្លែភាគច្រើនជាស្ត្រីក៏ដោយ។ ដូច្នេះ គឺមានសារៈសំខាន់ណាស់ក្នុងការកំណត់អត្តសញ្ញាណដោយប្រុងប្រយ័ត្ន ថាតើកត្តាអ្វីខ្លះដែលអាចនាំឱ្យមានសេចក្តីសម្រេចចិត្តថាជាកសិករគំរូដ៏ល្អម្នាក់ បន្ទាប់មកដាក់បញ្ចូលទៅក្នុងលក្ខខណ្ឌ ជំនាញ និងបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនដែលជាតម្រូវការ។





## ខាងក្រោមជាជំហានដែលអាចអនុវត្តតាមបានដើម្បីស្វែងរកកសិករគំរូដែលមានសក្ដានុពលៈ

## ក. រៀបចំតួនាទី ទំនួលខុសត្រូវ និងលក្ខណៈវិនិច្ឆ័យជ្រើសរើសកសិករគំរូ

- បុគ្គលិកគម្រោង និងដៃគូ អាចបំផុសគំនិតរួមគ្នា បង្កើតលក្ខណៈវិនិច្ឆ័យជ្រើសរើស តួនាទី និងទំនួលខុសត្រូវរបស់កសិករគំរូ។ អ្នកចូលរួមម្នាក់ៗគិតអំពីថាតើ តួនាទីផ្គត់ផ្គង់ធាតុចូលកសិកម្ម ទីផ្សារ និងបច្ចេកទេសកសិកម្មអ្វីខ្លះ ដែលកសិករគំរូគួរមានដើម្បីអនុវត្ត បន្ទាប់មកចែករំលែកគំនិតទាំងនេះដោយផ្អែកលើបទពិសោធន៍របស់ពួកគេធ្វើការជាមួយគម្រោង ឬសហគមន៍។

- តួនាទី និងទំនួលខុសត្រូវរបស់កសិករគំរូ អាចត្រូវបានធ្វើចំណាត់ថ្នាក់ជាបីប្រភេទដូចខាងក្រោម៖

| បច្ចេកទេស | ទីផ្សារ | ការផ្គត់ផ្គង់ធាតុចូលកសិកម្ម |
|---|---|---|
| • ផ្ដល់ដំបូន្មានផ្នែកកសិកម្មដល់កសិករ<br>• ជួយកសិករក្នុងការរៀបចំប្រតិទិនដំណាំ<br>• តាមដានការអនុវត្តរបស់កសិករ<br>• ជួយកសិករក្នុងការដោះស្រាយបញ្ហាផលិតកម្ម<br>• ស្វែងរកចំណេះដឹង បច្ចេកទេស និងបទពិសោធន៍ថ្មីៗ ដើម្បីចែករំលែកជាមួយកសិករ<br>• រៀបចំក្រុមកសិករផលិត<br>• ជួយកសិករក្នុងការពិនិត្យ និងតាមដានលើផលិតកម្មបន្លែ<br>• រៀបចំទិវាចំការបង្ហាញដល់ក្រុមកសិករ | • រៀបចំក្រុមកសិករដាំដុះបន្លែ<br>• ស្វែងរកទីផ្សារបន្លែថ្មីៗសម្រាប់កសិករ<br>• ចែករំលែកព័ត៌មានតម្លៃ និងតម្រូវការទីផ្សារបន្លែដល់កសិករ<br>• បណ្ដុះបណ្ដាលកសិករឱ្យចេះធ្វើចំណាត់ថ្នាក់បន្លែ វេចខ្ចប់ និងទុកដាក់<br>• សម្របសម្រួលកុងត្រាទិញ-លក់ រវាងក្រុមកសិករ និងក្រុមហ៊ុនប្រមូលទិញ<br>• សម្របសម្រួលជាមួយអាជីវករលក់រាយ និងលក់ដុំ<br>• ជួយកសិករក្នុងការរៀបចំផែនការផលិតកម្ម ផ្អែកទៅលើតម្រូវការទីផ្សារ | • ទំនាក់ទំនងជាមួយក្រុមហ៊ុន និងដេប៉ូផ្គត់ផ្គង់ធាតុចូលកសិកម្មរ<br>• ចែករំលែកព័ត៌មានអំពីធាតុចូលកសិកម្មផ្សេងៗ<br>• ណែនាំកសិករអំពីរបៀបប្រើប្រាស់ធាតុចូលកសិកម្មឱ្យបានត្រឹមត្រូវ<br>• ចរចាជាមួយអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម អំពីតម្លៃ និងគុណភាព<br>• ស្វែងរកដៃគូគាំទ្រនានាដូចជា អង្គការក្រៅរដ្ឋាភិបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>• ត្រួតពិនិត្យ និងពង្រឹងការអនុវត្តរបស់កសិករ |

- ពិចារណា និងពិភាក្សា ថាតើលក្ខណៈវិនិច្ឆ័យ/គុណសម្បត្តិអ្វីខ្លះ ដែលកសិករគំរូគួរមាន។ លក្ខណៈវិនិច្ឆ័យជ្រើសរើសគួរឆ្លើយតបទៅនឹងតួនាទី និងទំនួលខុសត្រូវដែលបានដាក់ចូលខាងលើ។ ខាងក្រោមគឺជាបញ្ជីសម្រាប់លក្ខណៈវិនិច្ឆ័យជ្រើសរើសកសិករគំរូ៖



១. មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងសហគមន៍/ភូមិ



២. ទទួលបានការគោរពពីអ្នកជិតខាង



៣. ជោគជ័យក្នុងផលិតកម្មបន្លែនិងមានផ្នត់គំនិតអាជីវកម្ម



៤. អាចអាន និងសរសេរបាន



៥. មានឆន្ទៈក្នុងការចូលរួម



៦. បើកចិត្តទូលាយ



៧. មានទំហំដីគ្រប់គ្រាន់សម្រាប់ធ្វើអាជីវកម្ម និងមធ្យោបាយធ្វើដំណើរ



៨. មិនមែនជាអ្នកប្រមឹកស្រា ឬលេងល្បែងពាលា

## ការវិនិយោគលើការកសាងសមត្ថភាពបុគ្គលិក

ដើម្បីអនុវត្តការភ្ជាស់គំនិតអាជីវកម្ម គម្រោងឈេនសូមណែនាំយ៉ាងមុតមាំឱ្យធ្វើការវិនិយោគលើការកសាងសមត្ថភាពបុគ្គលិករបស់អ្នកដើម្បីសម្របសម្រួលការបណ្ដុះបណ្ដាលការភ្ជាស់គំនិតអាជីវកម្មនេះ។ ទោះបីជាក្រុមការងារយើងបានបញ្ចូលជាតំណរភ្ជាប់ (Links) ទៅកាន់ម៉ូឌុលបណ្ដុះបណ្ដាលលម្អិត និងមានជាវីដេអូក្នុង Youtube បង្ហាញស្ដីពីការបណ្ដុះបណ្ដាលការភ្ជាស់គំនិតអាជីវកម្មនេះក៏ដោយ គម្រោងឈេនផ្ដល់យោបល់ឱ្យជួលអ្នកជំនាញផ្ដល់សេវាកម្មដូចជា SHE Investments ជាដើម ដើម្បីពង្រឹងសមត្ថភាពបុគ្គលិករបស់អ្នក។ សមត្ថភាពសាមញ្ញៗដែលបុគ្គលិករបស់អ្នកនឹងត្រូវការចាំបាច់ គឺជំនាញក្នុងការសម្របសម្រួល និងការយល់ដឹងអំពីការភ្ជាស់គំនិតអាជីវកម្មជាមូលដ្ឋាន។ គម្រោងឈេនណែនាំអ្នកឱ្យវិនិយោគលើកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្គោល (ToT) និងផ្ដល់វគ្គបង្ហាត់បង្ហាញ (Coaching)  សម្រាប់បុគ្គលិករបស់អ្នក។ ការចំណាយប៉ាន់ប្រមាណសម្រាប់ការបណ្ដុះបណ្ដាលសមត្ថភាពនេះគឺចំនួន ១០ ០០០ ទៅ ២០ ០០០ដុល្លារអាមេរិក។



## ខ. ការកំណត់អត្តសញ្ញាណកសិករគំរូ

- ប្រមូលឈ្មោះ និងព័ត៌មានទូទៅរបស់កសិករដាំដុះបន្លែនៅក្នុងតំបន់គោលដៅ ពិនិត្យមើលព័ត៌មានលម្អិតរបស់ពួកគេ និងធ្វើកំណត់ចំណាំលើអ្នកដែលដាំដុះដំណាំជាអាជីព។ វិធីនេះអាចធ្វើទៅបានតាមរយៈទំនាក់ទំនងដោយផ្ទាល់ជាមួយដៃគូគម្រោង និងអាជ្ញាធរមូលដ្ឋាន។

- រៀបចំបញ្ជីឈ្មោះកសិករទាំងនេះ និងទៅជួបពួកគេដោយផ្ទាល់ ឬអញ្ជើញពួកគេទៅកាន់ទីកន្លែងណាត់ជួបណាមួយ។

- ផ្ទៀងផ្ទាត់ព័ត៌មានទូទៅរបស់ពួកគេទៅនឹងលក្ខណៈវិនិច្ឆ័យជ្រើសរើស និងរៀបចំបញ្ជីឈ្មោះកសិករគំរូដែលមានសក្តានុពល។ ចំពោះអ្នកដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យជ្រើសរើសទាំងអស់ គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីក្លាយជាកសិករគំរូ ដូច្នេះសូមកត់ចំណាំឈ្មោះរបស់ពួកគេ បន្ទាប់មកទៅលេងនៅផ្ទះ តូប ឬនៅចំការរបស់ពួកគេ ដើម្បីពន្យល់អំពីអ្វីទៅជាកសិករគំរូ និងថាតើអ្វីខ្លះជាតួនាទី និងទំនួលខុសត្រូវដែលរំពឹងទុក។ ម្យ៉ាងទៀត គួរធ្វើការសង្កេតថាតើប្រតិបត្តិការរកស៊ី ឬការដាំដុះរបស់ពួកគេបានបង្ហាញអំពីចំណេះដឹងបច្ចេកទេសល្អដែរឬទេ។

## គ. សិក្ខាសាលាពិគ្រោះយោបល់

- រៀបចំសិក្ខាសាលាជាមួយបេក្ខជនជាកសិករគំរូដែលអ្នកបានកំណត់អត្តសញ្ញាណ ដើម្បីបង្ហាញអំពីគោលបំណងនៃកម្មវិធីភ្ជាប់គំនិតអាជីវកម្ម និងពិភាក្សាការចូលរួមរបស់ពួកគេក្នុងកម្មវិធីនេះ។

- កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលប្រសើរបំផុតដើម្បីរៀបចំសិក្ខាសាលា។

- មុនពេលព្រឹត្តិការណ៍ បុគ្គលិកគម្រោងគួររៀបចំសម្ភារអោយបានគ្រប់ជ្រុងជ្រោយសម្រាប់អ្នកចូលរួម និងជ្រើសរើសអ្នកសម្របសម្រួលសំខាន់ម្នាក់។

- ធ្វើការអញ្ជើញកសិករគំរូដែលមានសក្តានុពលដើម្បីចូលរួមសិក្ខាសាលា។ សួរអ្នកចូលរួមថាតើក្លាយខ្លួនជាកសិករគំរូ ពួកគេមើលឃើញសារៈប្រយោជន៍អ្វីខ្លះ។ សូមបន្ថែមទៅលើចម្លើយរបស់ពួកគេ ដើម្បីប្រាកដថាចំណុចសំខាន់ៗខាងក្រោមត្រូវបានបញ្ចូលដូចជា៖ ជួយដល់អ្នកដទៃ ជួយលើកស្ទួយសហគមន៍ ត្រូវបានទទួលស្គាល់នៅក្នុងសហគមន៍ និងរកចំណូលបានខ្ពស់ពីសកម្មភាពអាជីវកម្មរបស់ពួកគេ។

**កំណត់ចំណាំគន្លឹះ៖**
កម្មវិធីភ្ជាប់គំនិតអាជីវកម្មគ្របដណ្តប់ទិដ្ឋភាពពីរ៖ បច្ចេកទេសផលិតកម្មកសិកម្ម និងការភ្ជាប់គំនិតអាជីវកម្ម។ ពិតជាមានសារៈសំខាន់ណាស់ក្នុងការពន្យល់ខ្លឹមសារពីរនេះដល់កសិករគំរូដែលមានសក្តានុពល និងបញ្ជាក់ពីចំណាប់អារម្មណ៍របស់ពួកគេចំពោះកម្មវិធីនេះ។

- ពិពណ៌នាអំពីកម្មវិធីបណ្តុះបណ្តាល ពន្យល់ថាតើមានរយៈពេលប៉ុន្មាន (ការបណ្តុះបណ្តាលពេញមួយថ្ងៃក្នុងមួយសប្តាហ៍សម្រាប់រយៈពេលប្រាំខែ) និងពន្យល់អំពីអ្វីខ្លះដែលពួកគេនឹងរៀន។





- រៀបចំធ្វើការសង្កេតផ្ទាល់ខ្លីមួយអំពីប្រភេទអាជីវកម្មដែលបេក្ខជនចង់បង្កើត។ សំណួរនាំមុខ៖ តើអ្នកមានអាជីវកម្មហើយឬនៅ? ប្រសិនបើមានហើយ តើអ្នកចង់រៀនអំពីអ្វីដើម្បីអ្នកអាចធ្វើអោយអាជីវកម្មរបស់អ្នកប្រសើរឡើង ?តើជំនាញអ្វីខ្លះដែលសំខាន់សម្រាប់អ្នក ?ប្រសិនបើអ្នកពុំទាន់មានអាជីវកម្ម តើអាជីវកម្មប្រភេទណាដែលអ្នកមានបំណងចង់បង្កើត? ត្រូវបាកដថាកសិករដែលមានចំណាប់អារម្មណ៍ គឺមានឆន្ទៈក្នុងការចូលរួមពេញលេញក្នុងកម្មវិធីនេះ។ ព្យាយាមបញ្ចុះបញ្ចូលពួកគេអោយចូលរួមផ្លាស់ប្តូរគំនិតយោបល់កាន់តែច្រើនកាន់តែល្អ និងរក្សាការស្ងប់មតិនេះមិនផ្លូវការ និងពុំមានសម្ពាធឡើយ។ ទីបញ្ចប់ អ្នកសម្របសម្រួលប្រមូល និងច្របាច់បញ្ចូលគ្នានូវរាល់ការឆ្លើយតបទាំងអស់។ ខាងក្រោមគឺជាបញ្ជីប្រភេទអាជីវកម្មគំរូដែលកសិករគំរូប្រហែលជាចង់ចាប់ផ្តើម៖



១. អ្នកលក់ជុំ/អាជីវករ/អ្នកប្រមូលទិញ បន្លែ



២. អ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម



៣. អ្នកផ្គត់ផ្គង់កូនដំណាំ



៤. អ្នកតម្លើងប្រព័ន្ធតំណក់ទឹក



៥. អ្នកតម្លើងផ្ទះសំណាញ់

- ដើម្បីធ្វើការវិភាគបន្ថែមលើគុណសម្បត្តិរបស់កសិករគំរូដែលមានសក្តានុពល រៀបចំទម្រង់វាយតម្លៃខ្លួនឯង ដើម្បីវាយតម្លៃលក្ខណៈសេដ្ឋកិច្ច សង្គម ជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងបុគ្គលិកលក្ខណៈរបស់បេក្ខជននីមួយៗ។ សូមមើល**ឧបសម្ព័ន្ធ១** សម្រាប់ទម្រង់វាយតម្លៃខ្លួនឯងជាគំរូ។ ពន្យល់អំពីទម្រង់នោះ និងសុំអោយបេក្ខជនបំពេញព័ត៌មាន។ ផ្តល់ការគាំទ្របញ្ជាក់បន្ថែមប្រសិនមានតម្រូវការ។ អ្នកសម្របសម្រួលប្រមូលទម្រង់វាយតម្លៃខ្លួនឯងពីអ្នកចូលរួម និងបូកសរុបពិន្ទុ។ កសិករអាចដាក់ពិន្ទុរចន្លោះពី១ (ខ្សោយ) និង ១០ (ល្អណាស់)។ អ្នកសម្របសម្រួលអាចសួរទៅបេក្ខជនថាតើហេតុអ្វីពួកគេត្រូវដាក់ពិន្ទុជាក់លាក់ដោយខ្លួនឯង ហើយអញ្ជើញកសិករដទៃទៀតឱ្យមានប្រតិកម្មលើខ្លួន។



- បន្ទាប់មក សម្របសម្រួលការពិភាក្សាខ្លីមួយនៃតួនាទី និងទំនួលខុសត្រូវរបស់កសិករគំរូ ដើម្បីយល់ដឹងឱ្យបានច្បាស់ថាតើអ្វីដែលបេក្ខជនមើលឃើញថាជាសេវាកម្ម និងផលិតផលដែលកសិករភាគច្រើនអាចត្រូវការ និងអ្វីដែលពួកគេគិតថាពួកគេអាចផ្តល់បាន។

## ធ្វើការបែងចែកអ្នកចូលរួមជាក្រុមតូចៗ និងអនុញ្ញាតឱ្យពួកគេពិភាក្សានូវសំណួរមួយចំនួនដូចខាងក្រោម៖

១. តើអ្នកដឹងទេថាក្លាយជាកសិករគំរូ មានន័យដូចម្តេចទៅ?

២. តើលក្ខណៈវិនិច្ឆ័យសំខាន់ៗមានអ្វីខ្លះសម្រាប់ការក្លាយជាកសិករគំរូដ៏ល្អ?

៣. តើតួនាទី និងទំនួលខុសត្រូវរបស់កសិករគំរូមានអ្វីខ្លះ?

៤. តើអ្នកចង់បង្កើតអាជីវកម្មប្រភេទណា?

៥. តើសេវាកម្ម និងការគាំទ្រប្រភេទណាដែលអ្នកមានផែនការផ្តល់ទៅអោយកសិករដៃគូរបស់អ្នក?

៦. តើមានឱកាស និងបញ្ហាប្រឈមចំបងៗអ្វីខ្លះក្នុងការធ្វើការជាកសិករគំរូ?

៧. តើអ្នកកសាងទំនាក់ទំនងសហការល្អបែបណាជាមួយកសិករដទៃទៀតនៅក្នុងក្រុម ឬភាពជាអ្នកជិតខាងរបស់អ្នក?

- នៅក្នុងកិច្ចពិភាក្សាក្រុមធំ សូមឲ្យអ្នកចូលរួមម្នាក់ក្នុងមួយក្រុមឆ្លើយសំណួរមួយខាងលើ និងសុំគំនិត/យោបល់ បន្ទាប់មក ផ្លាស់ទៅក្រុមបន្ទាប់ និងឆ្លើយនូវសំណួរបន្ទាប់ទៀត។

## ឃ. ដៃគូសន្ទនានៅថ្នាក់ក្រោមជាតិ (អ្នកផ្តល់ព័ត៌មានសំខាន់ៗ)

- កំណត់អត្តសញ្ញាណអ្នកផ្តល់ព័ត៌មានសំខាន់ៗដែលអាចចូលរួមក្នុងអន្តរាគមន៍កសិករគំរូ រួមមាន៖ (១) វិស័យឯកជន ដូចជាអ្នកលក់រាយធាតុចូលកសិកម្ម អ្នកប្រមូលទិញ ។ល។ (២) ដៃគូអង្គការក្រៅរដ្ឋាភិបាល និង (៣) បុគ្គលិកមកពីទីភ្នាក់ងាររដ្ឋាភិបាល ដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាដើម។ សូមសម្ភាសន៍ពួកគេជាលក្ខណៈមិនផ្លូវការ មុនពេលអញ្ជើញពួកគេចូលក្នុងកិច្ចប្រជុំ។

- រៀបចំរបៀបណែនាំការសម្ភាសន៍ដាច់ដោយឡែកសម្រាប់អ្នកផ្តល់ព័ត៌មានសំខាន់ៗនីមួយៗ។ កម្រងសំណួរគួរតែបញ្ចូលសំណួរផ្សេងៗអំពីការយល់ឃើញ ដែលអ្នកផ្តល់ព័ត៌មានសំខាន់ៗទាំងនោះមានរួចជាស្រេច អំពីតួនាទីរបស់កសិករគំរូ ថាតើអ្វីដែលអ្នកផ្តល់ព័ត៌មានសំខាន់ៗគិតថាកសិករគំរូគួរធ្វើជាលក្ខណៈអាជីវកម្ម និងប្រភេទនៃការបណ្តុះបណ្តាល ដែលកសិករនឹងត្រូវទទួលបាន។ សូមមើល **ឧបសម្ព័ន្ធ២** អំពីគំរូរបៀបណែនាំកម្រងសំណួរ។

- អនុវត្តការសម្ភាសន៍ផ្ទាល់១ទល់នឹង១ ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដោយប្រើប្រាស់របៀបណែនាំការសម្ភាសន៍ ដើម្បីប្រមូលគំនិត ឬការយល់ឃើញរបស់ពួកគេចំពោះកសិករគំរូ។ សូមធ្វើការកត់ចំណាំ និងចងក្រងទុករាល់លទ្ធផលទាំងអស់។

- ប្រមូលព័ត៌មាន និងរៀបចំរបាយការណ៍សម្រាប់ការចែករំលែកបន្ត។ សូមរៀបចំបទបង្ហាញសង្ខេបសម្រាប់កិច្ចប្រជុំ។

- គួររៀបចំព្រឹត្តិការណ៍មួយដោយអញ្ជើញកសិករគំរូ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅក្នុងតំបន់គោលដៅនីមួយៗ ដើម្បីស្វែងយល់អំពីរបៀបដែលតួអង្គទីផ្សារអាចធ្វើការជាមួយកសិករគំរូ និងប្រភេទនៃការគាំទ្រដែលពួកគេអាចផ្តល់ជូនបាន។ សូមកំណត់ពេលវេលានៃកិច្ចប្រជុំតាមកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលសមរម្យ និងងាយស្រួលសម្រាប់ពួកគេចូលរួម។

- ក្នុងអំឡុងពេលនៃកិច្ចប្រជុំ បុគ្គលិករបស់គម្រោងដឹកនាំការពិភាក្សាអំពីឱកាស និងបញ្ហាប្រឈមនានារបស់អាជីវកម្មណាមួយដែលនាំកសិករចង់ចាប់ផ្តើម។ វិធីនេះអាចត្រូវបានចាប់ផ្តើមជាមួយនឹងបទបង្ហាញស្តីពីរបកគំហើញ ពីការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗទាំងនោះ។ សូមផ្តល់ពេលវេលា សម្រាប់អ្នកចូលរួមគ្រប់គ្នាដើម្បីសួរសំណួរ និងកត់ត្រាគ្រប់ចំណុចទាំងអស់នៅលើក្រដាសផ្ទាំងធំ។

- ប្រសិនបើក្រុមមានសមាជិកច្រើន ឬធំពេក ការពិភាក្សាអាចធ្វើឡើងជាក្រុមតូចៗ។ សូមបែងចែកអ្នកចូលរួមជាក្រុមតូចៗ ហើយជ្រើសរើសតំណាងក្នុងក្រុមនីមួយៗ។ ក្រុមនីមួយៗគួរតែមានការលាយបញ្ចូលគ្នារវាងកសិករ និងភាគីពាក់ព័ន្ធផ្សេងៗទៀត។

- ពិភាក្សាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសកសិករគំរូ កំណត់ថាតើនរណាអាចផ្តល់សេវាអ្វីខ្លះសម្រាប់កសិករគំរូក្នុងការចាប់ផ្តើមអាជីវកម្ម សេវាកម្មអ្វីខ្លះដែលកសិករគំរូត្រូវការចាំបាច់ និងថាតើគម្រោងអាចជួយសម្របសម្រួលទំនាក់ទំនងឈ្នះឈ្នះរវាងកសិករគំរូ និងតួអង្គវិស័យឯកជនដោយរបៀបណា។





# ចំណុចគន្លឹះ

១. រក្សារបញ្ជីឈ្មោះទំនាក់ទំនងអ្នកចូលរួមវិស័យឯកជនទាំងអស់ និងចែករំលែកទៅកាន់កសិករគំរូ ដើម្បីឱ្យពួកគេអាចទាក់ទងទៅដោយផ្ទាល់។

២. សម្រាប់វិស័យឯកជន ពេលវេលារបស់ពួកគេមានតម្លៃណាស់ ដូច្នេះត្រូវធានាថាកិច្ចប្រជុំគឺមានគោលបំណង និងផលិតភាពច្បាស់លាស់។ រក្សាកិច្ចប្រជុំអោយខ្លី និងលើកចំចំណុចសំខាន់ៗជាមួយនឹងបទបង្ហាញ និងកិច្ចពិភាក្សា។ សូមរំលេចនូវឱកាសនានាសម្រាប់វិស័យឯកជន។



៣. ត្រូវប្រាកដថាកិច្ចប្រជុំត្រូវបានរៀបចំយ៉ាងល្អជាមួយនឹងការផ្តល់ជូនឯកសារព័ត៌មានផ្សេងៗ បទបង្ហាញដែលគួរអោយទាក់ទាញ និងអាហារសម្រន់គ្រប់គ្រាន់សម្រាប់អ្នកចូលរួម។

# ៤.២ ការជ្រើសរើសកសិករគំរូ

ពិតជាមានសារៈសំខាន់ណាស់ក្នុងការបញ្ជាក់នូវការសម្រេចចិត្តរបស់បេក្ខជននីមួយៗម្តងហើយម្តងទៀតដើម្បីក្លាយជាកសិករគំរូ និងឆន្ទៈរបស់គាត់ក្នុងការចូលរួមពេញលេញក្នុងកម្មវិធីភ្ញាស់គំនិតអាជីវកម្ម ព្រមទាំងផែនការក្នុងការចាប់ផ្តើមអាជីវកម្មដែលបានជ្រើសរើស។

**ខាងក្រោមនេះគឺជាសកម្មភាពណែនាំមួយចំនួន៖**

- បុគ្គលិកគួរតែរៀបចំចុះពិនិត្យជាក់ស្តែងទៅកាន់កសិករគំរូនៅទីវាល ដើម្បីធ្វើការវាយតម្លៃឡើងវិញនូវការដាំដុះបន្លែ និងបទពិសោធន៍ទីផ្សាររបស់ពួកគេ។ បុគ្គលិកក៏គួរវាយតម្លៃទិសដៅអាជីវកម្មរបស់កសិករផងដែរ។ តើអាជីវកម្មប្រភេទណាដែលកសិករមានចំណាប់អារម្មណ៍? តើគាត់នឹងទទួលបានជោគជ័យលើដំណើរការអាជីវកម្មនោះដែរឬទេ?



- អំឡុងពេលជួបកសិករគំរូ បុគ្គលិកគួរតែបញ្ជាក់អំពីចំណាប់អារម្មណ៍របស់កសិករគំរូសក្តានុពលនៅក្នុងកម្មវិធី និងថាតើពួកគេមានពេលទំនេរគ្រប់គ្រាន់ដើម្បីចូលរួមដែរឬទេ។ ជាងនេះទៅទៀត អ្នកគួរតែសួរអំពីផែនការវិនិយោគរបស់ពួកគេ ទំហំដីធ្វើផលិតកម្ម និងថវិកាដែលពួកគេត្រូវរៀបចំសម្រាប់វិនិយោគ។

- កសិករគំរូសក្តានុពលដែលត្រូវគ្រប់ចំណុចនៃលក្ខណៈវិនិច្ឆ័យ ហើយបានយល់ និងព្រមព្រៀងលើតួនាទី និងទំនួលខុសត្រូវទាំងអស់ អាចចុះឈ្មោះដោយបំពេញលើទម្រង់បែបបទចុះបញ្ជី។ (សូមមើល **ឧបសម្ព័ន្ធ៣** សម្រាប់គំរូនៃទម្រង់ចុះឈ្មោះ ដែលបានដាក់បញ្ចូលនូវទំនួលខុសត្រូវសំខាន់ៗផងដែរ។)

- រៀបចំច្បាប់ចម្លងនៃទម្រង់ដែលបានចុះហត្ថលេខា និងប្រគល់ជូនទៅកសិករគំរូដែលបានចុះឈ្មោះ ដើម្បីពួកគេបានរំលឹកអំពីតួនាទីទំនួលខុសត្រូវ ព្រមទាំងការប្តេជ្ញាចិត្តរបស់ពួកគេ។

## ចំណុចគន្លឹះ

**១.** កសិករមួយចំនួនមានការស្ទាក់ស្ទើរដើម្បីក្លាយជាកសិករគំរូ ពីព្រោះពួកគេមិនទាន់ច្បាស់អំពីតួនាទី និងទំនួលខុសត្រូវ និង/ឬ ពួកគេមិនទាន់យល់អំពីប្រភេទអាជីវកម្មដែលសាកសមបំផុតសម្រាប់ពួកគេ។ បុគ្គលិកគួរតែពន្យល់នូវប្រភេទអាជីវកម្មផ្សេងៗដែលពួកគេអាចចាប់ផ្តើម និងស្នើជាយោបល់។ ជាការពិត កសិករគំរូអាចផ្លាស់ប្តូរប្រភេទអាជីវកម្មដែលពួកគេមានចំណាប់អារម្មណ៍ នៅមុនពេលកម្មវិធីបណ្តុះបណ្តាលចាប់ផ្តើម។

**២.** កសិករគំរូ គួរត្រូវបានចុះឈ្មោះយោងតាមចំណាប់អារម្មណ៍អាជីវកម្មដែលបានចែងនៅក្នុងទម្រង់។ គុណសម្បត្តិនៃការចុះបញ្ជីឈ្មោះពួកគេតាមប្រភេទអាជីវកម្មនេះគឺ (១) ជួយផ្តល់នូវកម្មវិធីបណ្តុះបណ្តាលសមត្ថភាពត្រឹមត្រូវ និង (២) ជួយបុគ្គលិកគម្រោងក្នុងការបន្តតាមដាន។

# ៤.៣ កម្មវិធីបណ្តុះបណ្តាលភ្ញាស់គំនិតអាជីវកម្ម និងការបង្ហាត់បង្ហាញ

## ការភ្ញាស់គំនិតអាជីវកម្មកសិករគំរូ គ្របដណ្តប់ការបណ្តុះបណ្តាលចំនួន២ប្រភេទគឺ៖ បច្ចេកទេសផលិតកម្ម និងការគ្រប់គ្រងអាជីវកម្ម។

កម្មវិធីត្រូវរៀបចំដើម្បីធានាថា កសិករគំរូមានចំណេះដឹង និងជំនាញគ្រប់គ្រាន់ដើម្បីប្រតិបត្តិអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេ។ ពិតជាមានសារៈសំខាន់ក្នុងការបញ្ជូនបុគ្គលិកគម្រោង ឬមន្ត្រីរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ បានចូលរួមរៀនសូត្រជាមុន នូវជំនាញចាំបាច់នានាពីអ្នកជំនាញបច្ចេកទេសកសិកម្ម និងភ្ញាស់គំនិតអាជីវកម្ម មុនពេលផ្តល់វគ្គបណ្តុះបណ្តាលបន្តទៅកាន់កសិករដែលបានចុះឈ្មោះរួច។ កសិករគំរូគួរតែរៀនសូត្រពីបុគ្គលិកគម្រោង ឬមន្ត្រីរដ្ឋាភិបាល គឺមិនផ្ទាល់ពីអ្នកជំនាញនោះទេ ពីព្រោះអ្នកជំនាញ ជាធម្មតាត្រូវជួលក្នុងតម្លៃខ្ពស់ ដោយសារពួកគេមិនមែនមកពី ឬរស់នៅក្នុងខេត្តនោះទេ ដូច្នេះពួកគេប្រហែលមិនមានពេលក្នុងការបណ្តុះបណ្តាលតាមដានបន្ត។ ម្យ៉ាងវិញទៀត កសិករគំរូអាចទទួលបានព័ត៌មានងាយស្រួលពីមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត ឬបុគ្គលិកគម្រោង ដែលពួកគេបានស្គាល់ស្រាប់។ នៅពេលកសិករគំរូបានចាប់ផ្តើមអាជីវកម្មរបស់ពួកគេ ពួកគេអាចចែករំលែកអ្វីដែលពួកគេបានរៀនជាមួយកសិករដទៃទៀតនៅក្នុងសហគមន៍របស់ពួកគេ។

សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសគម្រោងឈេនសូមណែនាំអោយជ្រើសរើសអ្នកជំនាញដែលមានបទពិសោធន៍បច្ចេកទេសល្អក្នុងផលិតកម្មបន្លែ។ពួកគេគួរតែមានចំណេះដឹងទូលំទូលាយក្នុងការដោះស្រាយបញ្ហាទូទៅនៅកម្រិតទីវាល ហើយធ្លាប់ធ្វើការជាមួយកសិករពីមុនមក។ កម្មវិធីសិក្សាស្តីពីបច្ចេកទេសត្រូវបានរៀបចំដោយទីប្រឹក្សាសាកវប្បកម្មគម្រោងឈេនដើម្បីដោះស្រាយគម្លាតចំណេះដឹងកសិករគំរូនិងកសាងជំនាញនានាក្នុងការដាំដុះបន្លែ និងគ្រប់គ្រងប្រតិបត្តិការសាកវប្បកម្ម។ សម្រាប់ការបណ្តុះបណ្តាលគម្រោងឈេនបានជួលក្រុមហ៊ុន SHE Investments ដើម្បីរៀមចំកម្មវិធីសិក្សា និងបណ្តុះបណ្តាលបុគ្គលិកគម្រោង និងមន្ត្រីរដ្ឋាភិបាលអំពីសហគ្រិនភាព និងការគ្រប់គ្រងអាជីវកម្មខ្នាតតូចជាមូលដ្ឋាន។

## ការណែនាំជាជំហានៗមានដូចខាងក្រោម៖

### ១. ការបណ្តុះបណ្តាលគ្រូបង្គោល (ToT)

- កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលត្រូវបានបែងចែកជា២ផ្សេងគ្នា ដោយរៀបចំផ្អែកទៅលើការសិក្សាវាយតម្លៃតម្រូវការសម្រាប់បណ្តុះបណ្តាល (សូមមើល**ឧបសម្ព័ន្ធ៤** សម្រាប់គំរូវាយតម្លៃ)។ ភាគីទី៣ដូចជា SHE Investments អាចអនុវត្តការបណ្តុះបណ្តាលអាជីវកម្មជាក្រុមខណៈពេលទីប្រឹក្សាបច្ចេកទេសរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសតាមកម្មវិធីសិក្សាកសិកម្មរបស់ខ្លួនដើម្បីគាំទ្រ និងបំពេញតម្រូវការរបស់កសិករគំរូលើគំរូអាជីវកម្មរបស់ពួកគេ។

### ២. ការបណ្តុះបណ្តាលអាជីវកម្ម (រយៈពេល៧ថ្ងៃ)

- ការបណ្តុះបណ្តាលអាជីវកម្មរួមមានសិក្ខាសាលាចំនួន៦វគ្គ ដែលសិក្ខាសាលានីមួយៗត្រូវចំណាយពេល១ថ្ងៃ ជាមួយនឹងពេលវេលាបន្ថែមចំនួន១ថ្ងៃ សម្រាប់រំលឹក និងបូកសរុប។ សិក្ខាសាលានីមួយៗរួមមានប្រធានបទមួយចំនួនដែលបានរៀបចំផ្អែកលើចំណាប់អារម្មណ៍របស់កសិករ និងគម្លាតចំណេះដឹងដោយបានកំណត់រកឃើញក្នុងអំឡុងពេលការវាយតម្លៃតម្រូវការសម្រាប់បណ្តុះបណ្តាល។





## គម្រោងឈេនសូមណែនាំនូវជំហានមួយចំនួនដូចខាងក្រោម៖

១. រៀបចំបញ្ជីឈ្មោះសិក្ខាកាម រួមបញ្ចូលទាំងបុគ្គលិកគម្រោង តំណាងមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងដៃគូពាក់ព័ន្ធនានា។ បញ្ជីឈ្មោះ តួនាទី លេខទូរស័ព្ទ និងអាសយដ្ឋានអ៊ីមែលរបស់ពួកគេត្រូវបានផ្ញើទៅភាគីដែលទទួលខុសត្រូវក្នុងការផ្តល់ការបណ្តុះបណ្តាលអាជីវកម្ម សម្រាប់ការចុះឈ្មោះ និងការបង្កើតគណនីអនឡាញ។

២. មុនពេលការបណ្តុះបណ្តាលចាប់ផ្តើម អ្នកចូលរួមដែលបានចុះឈ្មោះ នឹងទទួលបានសារក្នុងអ៊ីមែលពីគ្រូបណ្តុះបណ្តាលអាជីវកម្ម ដែលអញ្ជើញពួកគេឱ្យចូលទៅក្នុងគណនីអនឡាញដោយប្រើអាសយដ្ឋានអ៊ីមែលរបស់ពួកគេជាអត្តសញ្ញាណអ្នកប្រើប្រាស់។ នៅពេលដែលគណនីត្រូវបានចូលប្រើប្រាស់ សម្ភារៈនៃវគ្គសិក្សាទាំងអស់នឹងមាននៅទីនោះ រួមទាំងបទបង្ហាញ និងវីដេអូផ្សេងៗ។

៣. យ៉ាងហោចណាស់១ថ្ងៃមុនពេលចាប់ផ្តើមការបណ្តុះបណ្តាលក្នុងថ្នាក់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរតែពិនិត្យមើលទីកន្លែងសិក្ខាសាលា និងរៀបចំបញ្ជីសម្ភារៈដែលត្រូវប្រើប្រាស់។

៤. សម្រាប់ថ្ងៃទី១ គ្រូបណ្តុះបណ្តាលធ្វើបទបង្ហាញសង្ខេបអំពីមាតិកានៃវគ្គបណ្តុះបណ្តាលទៅកាន់អ្នកចូលរួម បន្ទាប់មកចាប់ផ្តើមបើកការបង្រៀនវគ្គដំបូង។ (យោងតាមឧបសម្ព័ន្ធ៥ ស្តីអំពីកម្មវិធីសិក្សាវគ្គអាជីវកម្មដែលរៀបរៀងដោយ SHE Investments)។

[៩] SHE Investments គឺជាសហគ្រាសសង្គមដែលមានឯកទេសក្នុងការរៀបចំ និងផ្តល់កម្មវិធីសិក្សាពន្លឿន និងភ្ជាស់គំនិតអាជីវកម្មសម្រាប់ស្ត្រីនៅប្រទេសកម្ពុជា។ សូមមើលគេហទំព័រ https://www.sheinvestments.com/#home សម្រាប់ព័ត៌មានលម្អិត

## ៣. វគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម (រយៈពេល១១ថ្ងៃ)

- សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម គម្រោងឈេនណែនាំអោយជ្រើសរើសទីប្រឹក្សាបច្ចេកទេសដែលមានបទពិសោធន៍ (បច្ចេកទេសកសិកម្ម/ក្សេត្រសាស្រ្ត) ដើម្បីរៀបចំកម្មវិធីសិក្សា និងបណ្តុះបណ្តាលបុគ្គលិកគម្រោង និង/ឬ មន្រ្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ពេលវេលានៃការសិក្សាសរុបមានរយៈពេល១១ថ្ងៃ ដែល៣ថ្ងៃគឺជាការបណ្តុះបណ្តាលទ្រឹស្តីក្នុងថ្នាក់ និង៨ថ្ងៃជាការបណ្តុះបណ្តាលនៅចំការ។ ការរៀបចំកម្មវិធីនៃវគ្គសិក្សា គឺផ្អែកលើការសិក្សាវាយតម្លៃតម្រូវការបណ្តុះបណ្តាល (សូមមើល**ឧបសម្ព័ន្ធ៦**)។

### គម្រោងឈេនសូមធ្វើការណែនាំនូវជំហានមួយចំនួនដូចខាងក្រោម៖

១. រៀបចំទីតាំងធ្វើចំការបង្ហាញសម្រាប់ការបណ្តុះបណ្តាលនៅចំការផ្ទាល់លើផលិតកម្មដំណាំដែលមានសក្តានុពល និងមានតម្រូវការទីផ្សារច្បាស់លាស់។

២. ទីប្រឹក្សាបច្ចេកទេសគួរតែចុះពិនិត្យមើលចំការដែលកសិករគំរូត្រូវចូលរួម ដើម្បីសង្កេតមើលថាតើបញ្ហាប្រឈមអ្វីខ្លះកំពុងកើតមាននៅទីវាល។ មន្រ្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏អាចត្រូវបានស្នើអោយជួយកំណត់នូវបញ្ហាប្រឈមនានាលើផលិតកម្មបន្លែដែលកើតមានជាញឹកញាប់នៅក្នុងតំបន់។

៣. រៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងបង្កើតកាលវិភាគបណ្តុះបណ្តាល ដោយផ្អែកលើព័ត៌មានដែលបានមកតាមរយៈការសង្កេតនៅទីវាលរបស់អ្នក និងទទួលបានពីមន្រ្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. អ្នកបច្ចេកទេសកសិកម្ម ផ្តល់វគ្គបណ្តុះបណ្តាលទ្រឹស្តីនៅក្នុងថ្នាក់ បន្ទាប់មករៀបចំធ្វើចំការបង្ហាញ និងការបណ្តុះបណ្តាលនៅទីវាល។ មន្រ្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរតែសុំទីធ្លាចំការរបស់កសិករដែលបានជ្រើសរើស សម្រាប់ធ្វើចំការបង្ហាញ។

៥. នៅក្នុងវគ្គសិក្សានីមួយៗ មន្រ្តីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការកត់ត្រា សួរសំណួរ និងរៀបចំការចែករំលែកការរៀនសូត្ររបស់ពួកគេជាមួយកសិករគំរូ។ គំរូកម្មវិធីសិក្សានៃវគ្គបច្ចេកទេសកសិកម្មត្រូវបានផ្តល់ជូននៅក្នុង **ឧបសម្ព័ន្ធ៧**។



## ៤. ការបណ្តុះបណ្តាលកសិករគំរូ

- យ៉ាងហោចណាស់មួយសប្តាហ៍មុន មន្ត្រីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទជូនដំណឹងទៅកសិករគំរូដែលបានចុះឈ្មោះ អំពីកាលបរិច្ឆេទដែលការបណ្តុះបណ្តាលភ្ញាស់គំនិតអាជីវកម្មនឹងចាប់ផ្តើម។

  កសិករគំរូភាគច្រើនមិនប្រើអ៊ីមែលទេ អ្នកខ្លះមិនមានអ៊ីនធឺណិតប្រើទាល់តែសោះ។ ប្រសិនកសិករប្រើតេឡេក្រាម អ្នកគួរតែបង្កើតក្រុមមួយសម្រាប់ថ្នាក់រៀនរបស់អ្នក ហើយអញ្ជើញកសិករគំរូឱ្យចូលរួមក្នុងក្រុមនោះ ដូច្នេះឯកសារផ្សេងៗអាចត្រូវបានចែករំលែកយ៉ាងលឿន និងងាយស្រួល។ កសិករមួយចំនួនប្រហែលជាមិនមានទូរស័ព្ទឆ្លាតវៃ ឬគណនីតេឡេក្រាមទេ ដូច្នេះមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក៏ត្រូវព្រីនសម្ភារៈសិក្សាផងដែរ សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់នៅក្នុងថ្នាក់រៀនផងដែរ។

  វត្តមានចូលរួមត្រូវបានកត់ត្រានៅរាល់វគ្គបណ្តុះបណ្តាល។ អ្នកចូលរួមគឺតម្រូវឱ្យចូលរៀនគ្រប់វគ្គទាំងអស់ ដើម្បីក្លាយជាកសិករគំរូជាផ្លូវការ។

  មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផ្ទេរចំណេះដឹងដែលទទួលបានពីគ្រូបណ្តុះបណ្តាលអាជីវកម្ម និងទីប្រឹក្សាបច្ចេកទេស ទៅកាន់កសិករគំរូដែលបានចុះក្នុងបញ្ជីឈ្មោះ យោងតាមកម្មវិធីសិក្សា និងកាលវិភាគ។ មុនពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគួរធ្វើតេស្តចំណេះដឹងរបស់កសិករគំរូ ដោយប្រើប្រាស់ទម្រង់តេស្ត ឬការវាយតម្លៃមុនការបណ្តុះបណ្តាល ។

  នៅចុងបញ្ចប់នៃថ្ងៃបណ្តុះបណ្តាលនីមួយៗ គ្រូបណ្តុះបណ្តាលគួរតែធ្វើការវាយតម្លៃលើការយល់ដឹងរបស់កសិករគំរូដោយសួរសំណួរសំខាន់ៗមួយចំនួន ឬធ្វើតេស្តក្រោយការបណ្តុះបណ្តាល។ ព័ត៌មានលម្អិតអំពីមាតិកានៃវគ្គសិក្សា សម្ភារៈ និងបទបង្ហាញអាចរកបានពី SHE Investments។ ព័ត៌មានទាំងនោះក៏អាចចូលមើលបានតាមរយៈ YouTube links នៅក្នុង **ឧបសម្ព័ន្ធ៥**។

  នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាល កសិករគំរូនីមួយៗត្រូវចងក្រងផែនការអាជីវកម្មមួយ និងសរសេរវាទៅក្នុងសៀវភៅរៀបចំផែនការអាជីវកម្ម។ សៀវភៅនេះត្រូវបានចងក្រង និងធ្វើការចែកចាយដោយគ្រូបណ្តុះបណ្តាល។

# ចំណុចគន្លឹះ

**១.** កសិករគំរូ ប្រហែលមានចំណាប់អារម្មណ៍លើគំរូអាជីវកម្មជាក់លាក់ ប៉ុន្តែពួកគេទាំងអស់គ្នាគួរតែចូលរួមជាមួយវគ្គសំខាន់ៗ (ស្នូល) មួយចំនួន។ សម្រាប់ការបណ្តុះបណ្តាលតាមគោលដៅកំណត់ជាច្រើនទៀត ពួកគេអាចចូលរៀនវគ្គពាក់ព័ន្ធនឹងអាជីវកម្មដែលពួកគេមានចំណាប់អារម្មណ៍។

**២.** ក្នុងវគ្គនីមួយៗ គ្រូបណ្តុះបណ្តាលគួរតែបញ្ចូលអោយមានល្បែងថាមពលកំសាន្ត ដើម្បីរក្សាចំណាប់អារម្មណ៍របស់សិក្ខាកាម និងជំរុញការចូលរួមរបស់ពួកគេ។

**៣.** កម្មវិធីបណ្តុះបណ្តាលមិនគួរប្រញាប់ប្រញាល់ពេកទេ។ គម្រោងឈេនសូមណែនាំកុំអោយអនុវត្តការបណ្តុះបណ្តាលនៅថ្ងៃជាប់ៗគ្នា។ ការបណ្តុះបណ្តាលគួរត្រូវបានរៀបចំពេញ១ថ្ងៃក្នុង១សប្តាហ៍គឺល្អបំផុត។

# ៤.៤ ការវាយតម្លៃលើការរៀនសូត្រ និងអភិវឌ្ឍន៍ផែនការអាជីវកម្ម

ការវាយតម្លៃលើការរៀនសូត្ររបស់កសិករគំរូ គឺអាចវាស់វែងនូវផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាល និងតេស្តសមត្ថភាពយល់ដឹងរបស់ពួកគេបន្ទាប់ពីបានបញ្ចប់ការរៀនសូត្រគ្រប់វគ្គដែលជាតម្រូវការទាំងអស់។

ការវាយតម្លៃត្រូវបានអនុវត្តដោយបុគ្គលិកគម្រោង។ ការដាក់ពិន្ទុគឺពាក់ព័ន្ធនឹងការវាយតម្លៃចំនួន២៖ ការអនុវត្តក្នុងថ្នាក់រៀន និងការសង្កេតនៅលើទីវាល ឬនៅទីតាំងអាជីវកម្ម។ លទ្ធផលនៃការវាយតម្លៃអាចបង្ហាញចេញនូវចំណុចខ្លាំង និងចំណុចខ្សោយរបស់កសិករគំរូ និងអាចណែនាំដល់គ្រូបណ្តុះបណ្តាលអំពីថាតើចំណុចអ្វីខ្លះដែលអាចធ្វើឱ្យប្រសើរឡើងជាងនេះ។

## ខាងក្រោមគឺជាជំហានដែលអាចអនុវត្តបាននៅពេលរៀបចំការវាយតម្លៃ៖

- បុគ្គលិកគម្រោងគួររៀបចំវិធីសាស្ត្រជាមុន និងអញ្ជើញអ្នកពាក់ព័ន្ធទាំងនោះ ដើម្បីធ្វើការសម្រេចចិត្ត (សមាជិកគណៈកម្មការ)។
- នៅថ្ងៃធ្វើការវាយតម្លៃ កសិករគំរូដែលបានបញ្ចប់គ្រប់វគ្គបណ្តុះបណ្តាលទាំងអស់ រៀបចំផែនការអាជីវកម្មមួយដោយប្រើប្រាស់គំរូដែលផ្តល់ជូនពីគ្រូបណ្តុះបណ្តាល។
- ការរៀបចំផែនការអាជីវកម្មអាចធ្វើឡើងក្នុងរយៈពេលមួយថ្ងៃ ឬបន្តទៅថ្ងៃបន្ទាប់ អាស្រ័យលើសមត្ថភាពរបស់កសិករ។ ដើម្បីបញ្ចប់ផែនការអាជីវកម្ម កសិករគំរូគួរពិភាក្សាជាមួយគ្រួសារ ឬប្តី/ប្រពន្ធជាមុនសិន។ សូមមើលឧបសម្ព័ន្ធ៨ សម្រាប់គំរូផែនការអាជីវកម្ម។



- នៅពេលដែលកសិករគំរូបានរៀបចំផែនការអាជីវកម្មរួចរាល់ ការវាយតម្លៃត្រូវបានធ្វើឡើង។ គណៈកម្មការធ្វើការវាយតម្លៃការងាររបស់កសិករគំរូនីមួយៗ ហើយកត់ត្រាចូលក្នុងទម្រង់ដាក់ពិន្ទុ។ ការដាក់ពិន្ទុគឺធ្វើឡើងដោយសមាជិកនៃគណៈកម្មការ រួមមាន គ្រូបណ្តុះបណ្តាល បុគ្គលិកគម្រោងដៃគូ មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាដើម ដោយផ្អែកលើការសម្ភាសន៍ និងការសង្កេតក្នុងអំឡុងពេលបណ្តុះបណ្តាល។
- ប្រមូលទម្រង់ដែលបានដាក់ពិន្ទុពីសមាជិកគណៈកម្មការទាំងអស់ ហើយធ្វើការបូកសរុប។ កសិករគំរូដែលមានពិន្ទុខ្ពស់ជាងគេ អាចទទួលបានរង្វាន់លើកទឹកចិត្ត ឬដើមទុនចាប់ផ្តើមអាជីវកម្ម។ សូមមើលការណែនាំអំពីការគាំទ្រដើមទុនចាប់ផ្តើមនេះ និងរង្វាន់លើកទឹកចិត្តសម្រាប់កសិករគំរូនៅក្នុងឧបសម្ព័ន្ធ៩។
- កសិករគំរូដែលមានផែនការអាជីវកម្មល្អ បានពិន្ទុសរុបខ្ពស់លើការវាយតម្លៃ និងបានចូលរួមយ៉ាងពេញលេញក្នុងកម្មវិធីបណ្តុះបណ្តាល នឹងទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សា ក្លាយកសិករគំរូជាផ្លូវការ ដែលចុះហត្ថលេខាដោយបុគ្គលិករបស់គម្រោង និងថ្នាក់ដឹកនាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- វិញ្ញាបនបត្រ ត្រូវបានផ្តល់ជូនតាមរយៈការរៀបចំពិធីតូចមួយដែលចូលរួមដោយបុគ្គលិកគម្រោង មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងកសិករគំរូ។



រូបថតទី១៖ កសិករទទួលបានវិញ្ញាបនបត្របន្ទាប់ពីបញ្ចប់ការសិក្សា

# ចំណុចគន្លឹះ

**១.** កាបណ្តុះបណ្តាលរំលឹកឡើងវិញប្រហែលជាត្រូវការចាំបាច់ប្រសិនបើបុគ្គលិកគម្រោងសង្កេតឃើញថា កសិករគំរូមានភាពលំបាកក្នុងការចងចាំខ្លឹមសារនៃវគ្គទាំងអស់ និង/ឬ មិនបានប្រើប្រាស់ការរៀនសូត្ររបស់ពួកគេអោយមានប្រសិទ្ធភាព។

**២.** ផ្អែកលើការស្រាវជ្រាវរបស់កសិករគំរូ និងបទពិសោធន៍របស់គម្រោង កសិករគំរូត្រូវការចាំបាច់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុដើម្បីចាប់ផ្តើមអាជីវកម្មថ្មីរបស់ពួកគេ ដូច្នេះគម្រោងឈេនបានផ្តល់ជូនដើមទុនចាប់ផ្តើមចំនួន ២៥០ដុល្លារ ដល់កសិករគំរូដែលបានបញ្ចប់វគ្គសិក្សា។

**៣.** គម្រោងឈេនបានបង្កើតកម្មវិធី « ពានរង្វាន់សម្រាប់ការចាប់ផ្តើមអាជីវកម្មបានល្អជាងគេ» សម្រាប់កសិករគំរូដើម្បីធ្វើការប្រកួតប្រជែងក្នុងចំណោមពួកគេ។ អ្នកដែលបានផ្តល់សេវាកម្មបានប្រសើរជាងគេទៅកាន់កសិករដទៃទៀត និងបានរៀបចំសំណើអាជីវកម្មបានល្អគឺមានសិទ្ធគ្រប់គ្រាន់ក្នុងការទទួលបានពានរង្វាន់នេះ។ ការវាយតម្លៃត្រូវបានរៀបចំដោយបុគ្គលិកគម្រោង។ ពានរង្វាន់ប្រកួតប្រជែងនេះគឺជារង្វាន់ដែលត្រូវផ្តល់ជូនកសិករគំរូចំនួន២នាក់នៅក្នុងតំបន់គោលដៅនីមួយៗ ដែលម្នាក់ៗទទួលបានទឹកប្រាក់ ១.០០០ដុល្លារ ដើម្បីវិនិយោគក្នុងការចាប់ផ្តើមអាជីវកម្មរបស់ពួកគេបន្ថែមពីលើដើមទុនចាប់ផ្តើមចំនួន២៥០ដុល្លារ។

# ៤.៥ ការផ្គូផ្គង និងការគាំទ្រការចាប់ផ្តើមអាជីវកម្ម ( ការបង្ហាត់បង្ហាញ និងការផ្តល់ដើមទុនចាប់ផ្តើមអាជីវកម្ម )

ការផ្គូផ្គងអាជីវកម្មគឺជាការផ្សារភ្ជាប់កសិករគំរូជាមួយដៃគូពាក់ព័ន្ធដូចជា ក្រុមហ៊ុនវិស័យឯកជន ក្រុមហ៊ុនដែលកំពុងស្វែងរកដៃគូបណ្តាក់ទុនរួមគ្នា អង្គការក្រៅរដ្ឋាភិបាល និងបណ្តាញចែកចាយ ឬភ្នាក់ងារនៅក្នុងតំបន់នានា។ ការផ្គូផ្គងអាចធ្វើឡើងក្នុងអំឡុងពេល ឬបន្ទាប់ពីកម្មវិធីបណ្តុះបណ្តាល ដោយផ្អែកលើការស្នើសុំពីកសិករគំរូ និងភាគីពាក់ព័ន្ធ។ វិធីសាស្ត្រនេះផ្តល់ឱកាសដល់អ្នកដែលបានបញ្ចប់វគ្គភ្ជាស់គំនិតអាជីវកម្មបានបង្កើតបណ្តាញសហប្រតិបត្តិការផ្សេងៗ។

ការផ្គូផ្គងរវាងភាគីទាំងពីរ - កសិករគំរូ និងតួអង្គវិស័យឯកជន គួរតែត្រូវបានអនុវត្តក្រោមការគ្រប់គ្រងរបស់នរណាម្នាក់ដែលអាចធានាបាននូវកិច្ចព្រមព្រៀងប្រកបដោយជោគជ័យ - អាចជាអាជ្ញាធរមូលដ្ឋាន អ្នកសម្របសម្រួលគម្រោង ឬមន្ត្រីរដ្ឋាភិបាល/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ជំហានជាអនុសាសន៍សម្រាប់ការផ្គូផ្គងអាជីវកម្មត្រូវបានផ្តល់ដូចខាងក្រោម៖**

- អញ្ជើញកសិករគំរូ និងតួអង្គវិស័យឯកជន ដើម្បីជួប និងពិភាក្សាគ្នាអំពីកិច្ចសហប្រតិបត្តិការអាជីវកម្ម។
- ផ្គូផ្គងកសិករគំរូនីមួយៗដោយឡែកៗជាមួយអាជីវករប្រមូលទិញបន្លែ និងតួអង្គវិស័យឯកជននៅក្នុងតំបន់ដូចជា ក្រុមហ៊ុនផ្គត់ផ្គង់គ្រាប់ពូជ អ្នកលក់ធាតុចូលកសិកម្ម និងអ្នកតម្លើងផ្ទះសំណាញ់ អាស្រ័យលើអាជីវកម្មដែលកសិករមានចំណាប់អារម្មណ៍។
- ក្នុងអំឡុងពេលផ្គូផ្គង កសិករគំរូគួរតែធ្វើបទបង្ហាញសង្ខេបអំពីចំណាប់អារម្មណ៍អាជីវកម្ម ផែនការអាជីវកម្ម ថវិកាសម្រាប់វិនិយោគ ទីតាំងអាជីវកម្មរបស់ពួកគេ និងប្រភេទសេវាកម្មគាំទ្រដែលពួកគេត្រូវការចាំបាច់។ តួអង្គវិស័យឯកជនអាចរៀបរាប់អំពីប្រភេទគាំទ្រដែលពួកគេអាចផ្តល់ទៅកាន់កសិករគំរូទាំងនោះ។
- ប្រសិនបើគូភាគីជាអាជីវករប្រមូលទិញបន្លែ សូមនាំពួកគេទៅមើលទីវាលចំការដាំដុះរបស់កសិករគំរូ។ សម្រាប់តួអង្គវិស័យឯកជន សូមនាំពួកគេទៅកាន់ទីតាំងហាង ឬតូបរបស់កសិករគំរូ។



- ដំណើរការចុះកិច្ចសន្យាអាជីវកម្មគួរត្រូវបានរៀបចំឡើងក្រោមការគ្រប់គ្រងរបស់នរណាម្នាក់ដែលអាចពឹងពាក់បានដូចជា បុគ្គលិកគម្រោង ឬមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីប្រឹក្សា ឬអាជ្ញាធរមូលដ្ឋាន។ អ្នកទាំងនេះក៏អាចចូលរួមគាំទ្រតាមរយៈការរៀបចំឯកសារដែលចាំបាច់ រួមមាន កិច្ចសន្យា ទម្រង់បែបបទផ្សេងៗ។ល។

ទោះបីជាកសិករគំរូដែលបានចុះឈ្មោះបានអភិវឌ្ឍផែនការអាជីវកម្មដោយខ្លួនឯង និងមាននៅក្នុងដៃរបស់ពួកគេក៏ដោយ ពួកគេប្រហែលនៅតែត្រូវការ ការគាំទ្រអំពីរបៀបចាប់ផ្តើមអនុវត្តអាជីវកម្មជាក់ស្តែងរបស់ពួកគេ។ ដូច្នេះហើយ ការគាំទ្រការចាប់ផ្តើមអាជីវកម្មគឺមានភាពចាំបាច់ដើម្បីប្រាកដថាអាជីវកម្មរបស់ពួកគេមានដំណើរការល្អ និងអាចរកប្រាក់ចំណូលបាន។ គ្រូបណ្តុះបណ្តាលគួរតែធ្វើការបង្វឹកកសិករម្នាក់ៗ ទាំងដោយផ្ទាល់ ឬតាមរយៈទូរស័ព្ទដូចខាងក្រោម៖

- មកពិនិត្យមើលទីតាំងចាប់ផ្តើមអាជីវកម្ម ឬទីតាំងដែលកសិករចង់បង្កើតហាង ឬតូប និងផ្តល់យោបល់ដល់ពួកគេអំពីការរចនា និងការតុបតែងហាង ឬតូបដែលសមរម្យ ប្រភេទឧបករណ៍ ឬទំនិញដែលគួរបញ្ជាទិញ និងរបៀបលក់ទៅកាន់អ្នកទិញ។

- តាមដានដំណើរការចាប់ផ្តើមរបស់កសិករដោយធ្វើការពិនិត្យមើលសៀវភៅកត់ត្រាអាជីវកម្មរបស់ពួកគេ។ ប្រសិនបើអ្នករកឃើញថាអាជីវកម្មមិនដំណើរការល្អ សូមប្រាប់ពួកគេ ផ្តល់យោបល់ និងបណ្តុះបណ្តាលពួកគេម្តងទៀតនៅនឹងកន្លែង។

# ចំណុចគន្លឹះ

**១.** កសិករអាចនឹងភ្លេចលឿននូវអ្វីដែលពួកគេបានរៀន ជាពិសេសមេរៀនអាជីវកម្ម។ សូមរក្សាលេខទំនាក់ទំនងរបស់ពួកគេ និងបញ្ចូលទៅក្នុងតេឡេក្រាម ឬប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងទៀត ដើម្បីអ្នកងាយស្រួលទាក់ទងទៅពួកគេ។

**២.** ប្រសិនបើកសិករគំរូស្នើសុំការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការចាប់ផ្តើមអាជីវកម្មរបស់ពួកគេ គម្រោងគួរតែណែនាំអំពីផែនការសហវិនិយោគ ឬឱកាសទទួលបានប្រាក់កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI)។



# ៥. សន្និដ្ឋាន



ខណៈពេលគោលការណ៍ និងវិធីសាស្ត្រទាំងឡាយដែលបានលើកឡើងផ្តោតសំខាន់លើសាកវប្បកម្ម អាចអនុវត្តបានចំពោះផលិតផល និងទីផ្សារផ្សេងៗជាច្រើន គម្រោងឈេនសង្ឃឹមយ៉ាងមុតមាំថានឹងអាចជំរុញអង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់ក្រោមជាតិនានាក្នុងប្រទេសកម្ពុជា ទទួលយកទៅអនុវត្តនូវវិធីសាស្ត្រភ្ញាស់គំនិតអាជីវកម្មកសិករគំរូ ដែលបានផ្តល់លទ្ធផលដ៏មានតម្លៃសម្រាប់គម្រោងឈេននេះ។ វាគឺជាការផ្តួចផ្តើមគំរូការងារប្រកបដោយនិរន្តរភាពសម្រាប់កសិករដែលបានជ្រើសរើសដើម្បីផ្តល់សេវាកម្មដែលមានអត្ថប្រយោជន៍ (ដូចជា ការផ្សព្វផ្សាយ និងព័ត៌មានទីផ្សារជាដើម) នៅក្នុងសហគមន៍របស់ពួកគេ ព្រមទាំងអនុញ្ញាតឱ្យពួកគេទទួលបានចំណេះដឹងថ្មីៗផងដែររួមមានការបង្កើតបណ្តាញទំនាក់ទំនងជាមួយវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត និងការជំរុញលើកទឹកចិត្តពួកគេឱ្យចាប់ផ្តើមអាជីវកម្ម។

ដើម្បីចូលទៅប្រើប្រាស់សៀវភៅណែនាំរបស់គម្រោងឈេន (ជាភាសារខ្មែរ) ទៅលើបច្ចេកវិទ្យាកសិកម្មជាក់លាក់ និងបច្ចេកទេសសាកវប្បកម្ម សូមចូលមើលនៅបណ្ណាល័យអនឡាញ (e-library) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈគេហទំព័រ (https://elibrary.maff.gov.kh)។

